01506323

E1/280.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 04-Jul-2017, 14:34
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៩នាទី**

**សវនាការលើកទី២៦១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms. Maddalena Ghezzi)*

កញ្ញា ជា ស៊ីវហ៊ាង

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក សេង លាង

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក សួន វិសាល

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន

*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក វៀល សន (2-TCW-860) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក រៀល សន** (2-TCW-860)

សួរបន្តដោយលោក គង់ សំអុន ផ្ដើមពី ....................................................................ទំព័រ ៣
សួរដោយលោក អាកទូរ វែកគែន ផ្ដើមពី ...............................................................ទំព័រ ១២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:២២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះអង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី រៀល សន បញ្ចប់ ហើយនិងអាចចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-822។ ហើយមូលហេតុដែលយើងប្រើពាក្យ “អាច” នេះដោយសារគាត់មានបញ្ហាសុខភាព បញ្ហាសម្ពាធឈាមឡើងខ្ពស់កាលពីម្សិលមិញ។ ហើយថ្ងៃនេះ ព្រឹកនេះគ្រូពេទ្យកំពុងតែពិនិត្យតាមដាននូវសុខភាពរបស់គាត់ ដើម្បីវាយតម្លៃថាតើគាត់អាចផ្តល់សក្ខីកម្មនៅពេលវេលាចុងក្រោយនៃដំណើរការសវនាការថ្ងៃនេះដែរឬយ៉ាងណា។ ហើយទី២ គឺអង្គជំនុំជម្រះបានជម្រាបជូនភាគីរួចហើយម្សិលមិញ គឺថានៅសវនាការថ្ងៃនេះ យើងមានពេល យើងនឹងស្តាប់សារណាផ្ទាល់មាត់របស់ភាគីលើសំណើសុំរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលសុំឲ្យអង្គជំនុំជម្រះស្តាប់នូវសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី D22/2500 ដែលមានឯកសារ E344 និង E344.1 ដោយរួមទាំងសុំទទួលយកឯកសារថ្មីពាក់ព័ន្ធជាមួយនឹងបញ្ហាសំណើសុំស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីនោះផង សូមភាគីជ្រាប។

ក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកបានស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះគឺលោក រៀល សន។ លោក និងលោកមេធាវីប្រឹក្សាលោក ឌុច ផារី មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ នៅថ្ងៃនេះមានសាក្សីបម្រុងមួយរូបដែលមាន

របស្សនាម 2-TCW-822។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនៅវេលាម៉ោងដប់ព្រឹកនេះ។

អរគុណលោកប្រធាន។

[០៩:១២:២៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ហើយឥឡូវនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាពេលខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និង មានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី១៩ ខែមីនា ២០១៥។

មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។ បានឃើញកំណត់ហេតុពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះរ៉ាំរ៉ៃ វិលមុខ មិនអាចអង្គុយបានយូរ ហើយនិងផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញ១ថ្ងៃនេះ។

ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។

[០៩:១៤:១៤]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងអំឡុងពេលនៃដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ខៀវ សំផន អង្គជំនុំជម្រះសូមបង្គាប់ឲ្យក្រឡាបញ្ជីសវនាការសហការជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការប្រាប់ និងជម្រាបដល់សាក្សីដែលមានរហស្សនាម -- សាក្សីបម្រុង TCW-822 ដើម្បីឲ្យដឹងលទ្ធផល លទ្ធភាពនៃការអាចដំណើរការផ្តល់សក្ខីកម្មនៅចំពោះមុខសវនាការបានដែរឬយ៉ាងណា។ ហើយជម្រាបគាត់ផងថា បើសិនបើស្ថានភាពសុខភាពគាត់មិនអំណោយផលមិនអាច ទំនងជាមិនអាចផ្តល់សក្ខីកម្មបានទេ ឲ្យរាយការណ៍មកអង្គជំនុំជម្រះឲ្យបានមុនពេលដែលអង្គជំនុំជម្រះនឹងបញ្ចប់ការស្តាប់សក្ខីកម្មសាក្សី រៀល សន។

បាទ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី រៀល សន។ សូមអញ្ជើញ!

[០៩:១៥:៣២]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក គង់ សំអុន៖**

**ស៖** លោកសាក្សីខ្ញុំសុំអនុញ្ញាតបន្តសំណួររបស់ខ្ញុំ។ កាលពីម្សិលមិញយើងបានពិភាក្សាអំពីការទទួលខុសត្រូវរបស់លោក ហើយក៏មានរចនាសម្ព័ន្ធរបស់មន្ទីរពេទ្យស្រុកដែលលោកធ្វើការ។ ឥឡូវខ្ញុំចង់សួរបន្ថែមទាក់ទងទៅនឹងក្រមសីលធម៌របស់ពេទ្យ។ ខ្ញុំចង់ដឹងថា តើនៅក្នុងមន្ទីរពេទ្យរបស់លោកមានការប្រជុំពិភាក្សាទៅលើការគោរពវិន័យចំពោះពេទ្យក្នុងការផ្តល់សេវាដល់សាធារណជនទេនៅពេលនោះ?

**លោក រៀល សន៖**

**ឆ៖** បាទ នៅពេលនោះគឺប្រជុំការងារក្រុមសីលធម៌នេះគឺ ខ្ញុំបាទប្រជុំរៀងរាល់សប្តាហ៍។ បើទោះបីអត់មានបញ្ហាអីក៏ប្រជុំដែរ ប្រជុំថ្ងៃហ្នឹងហើយ ណាត់គ្នាប្រជុំថ្ងៃក្រោយទៀតដាក់ថ្ងៃប្រជុំ ដើម្បីកុំឲ្យខ្វះវិន័យ បុគ្គលិកខ្វះវិន័យនៅក្នុងមន្ទីរពេទ្យ។ ទោះបីជាមានរវល់មមាញឹកយ៉ាងណាក៏ដោយចុះ ក៏ខ្ញុំត្រូវតែប្រជុំដែរ ព្រោះខ្លាចអាវិន័យហ្នឹងវាខ្ចាត់ភ្លាត់ តែមួយថ្ងៃខ្ចាត់ភ្លាត់បានហើយ។

[០៩:១៧:១៨]

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់អំពីវិន័យដែលលោកមានសម្រាប់បុគ្គលិកពេទ្យនៅក្នុងមន្ទីរពេទ្យរបស់លោកបានទេ មានជាអ្វីខ្លះ?

**ឆ៖** បាទ វិន័យនៅក្នុងមន្ទីរពេទ្យមានវិន័យឲ្យបុគ្គលិកពេទ្យហ្នឹងសុភាពរាបសាជាមួយនឹងអ្នកជំងឺ ចាក់ថ្នាំក៏ ពេលចាក់ថ្នាំហ្នឹងក៏មិនឲ្យមានបញ្ហា និយាយរួមមួយក្រុមសីលធម៌របស់ពេទ្យហ្នឹង ទាំងអស់។

**ស៖** តើលោកអាចបញ្ជាក់បានទេថា ក្នុងរយៈពេលដែលលោកធ្វើការនៅក្នុងមន្ទីរពេទ្យហ្នឹង ដែលមានករណីណាមួយដែលទាក់ទងទៅនឹងការល្មើសវិន័យ ឬក៏ក្រមសីលធម៌ពេទ្យដែរទេ? ហើយលោកចាត់វិធានការដូចម្តេចចំពោះបុគ្គលិកពេទ្យដែលមានបញ្ហាបែបនេះ?

**ឆ៖** បាទ បញ្ហានេះមានតើ! នៅក្នុងមន្ទីរពេទ្យខ្ញុំមាន។ មានបញ្ហាមួយខុសសីលធម៌ នារីហើយនិងនារី មួយប្តីមួយប្រពន្ធ។ អ៊ីចឹង ខ្ញុំបាទសុំចៅហ្វាយស្រុកប្តូរមួយចេញពីកន្លែង ប្តីចេញពីកន្លែងខ្ញុំទៅនៅប្រពន្ធហ្នឹង ហើយប្តីនោះទៅនៅពេទ្យ អង្គាល់ហ្នឹងខ្ញុំភ្លេចហើយមិនដឹងទៅនៅពេទ្យណា។

**ស៖** ករណីនេះ លោកចង់និយាយអំពីមនុស្សស្រីពីរនាក់ស្រឡាញ់គ្នា។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ស្រឡាញ់អ្នកភេទដូចគ្នា។

**ស៖** បាទ ខ្ញុំសំណួររបស់ខ្ញុំ ខ្ញុំសួរទាក់ទងទៅនឹងការអនុវត្តក្រមសីលធម៌ពេទ្យ។ តើអ្វីដែលជាការអនុវត្តផ្នែកវិជ្ជាជីវៈពេទ្យ ដែលលោកគិតថា មានអំពើល្មើសណាមួយទាក់ទងទៅនឹងការអនុវត្តក្រមសីលធម៌ពេទ្យ ឬក៏វិន័យពេទ្យដែលលោកបានអប់រំបុគ្គលិករបស់លោកនោះ។ តើមានករណីបែបហ្នឹងទេ? ហើយជាករណីអ្វីដែរ?

[០៩:២០:១៨]

**ឆ៖** បាទ កាលនោះដូចជាគ្មានទេ បើៗមានប៉ុនធាតុពិតគឺគ្មានហ្នង បើផ្នែកនារីគេមានក៏គេ

វាយការណ៍ប្រាប់ខ្ញុំផ្នែកបុរសដែរ ហើយបើខ្ញុំផ្នែកបុរសមានបញ្ហាហ្នឹងក៏វាយការណ៍ប្រាប់គេផ្នែកនារីដែរ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងករណីផ្ដល់សេវា ឧទាហរណ៍មានការទទួលពាក្យបណ្ដឹងពីអ្នកជំងឺ ពីការដែលពេទ្យសម្ដីមិនល្អ ឬក៏មានការប្រព្រឹត្តណាមួយមិនគប្បីចំពោះអ្នកជំងឺ តើមានករណីបែបហ្នឹងទេ?

**ឆ៖** បាទមានដែរ កាលនុ៎ងមានដែរ បុគ្គលិកក្មេងៗច្រើនតែខុសពាក្យសម្ដីហ្នឹង ប៉ុន្តែខ្ញុំបាទយើងខ្ញុំនឹងហៅមកអប់រំណែនាំភ្លាម។

**ស៖** លោកអាចពន្យល់អង្គជំនុំជម្រះថាលោកអប់រំយ៉ាងដូចម្ដេចបានទេ?

**ឆ៖** បាទគ្រាន់តែប្រាប់អ្នកដែលធ្វើខុសហ្នឹងថា ឲ្យលែងធ្វើអីចឹងទៀត ខ្លីៗតែបន្តិចហ្នឹងឲ្យទៅវិញទៅ។ មិនមានដាក់ទោសដាក់ពៃរ៍ ដាក់ទណ្ឌកម្មអីទេ។

**ស៖** ក្នុងការគ្រប់គ្រងបុគ្គលិកពេទ្យ លោកដឹងថាតើបុគ្គលិកពេទ្យរបស់លោកមកពីតំបន់ណាខ្លះទេ?

**ឆ៖** បាទដឹងបុគ្គលិកពេទ្យខ្ញុំកាលនុ៎ងគឺនៅតំបន់តាកែវទាំងអស់ មានតែនារី ហាន មួយដែលយើងលើកឡើងពីម្សិលមិញហ្នឹង ដែលគេបញ្ជូនមកហ្នឹង ថាផ្ទះនៅកំពង់ឆ្នាំង មានតែមួយហ្នឹង។

[០៩:២៣:០០]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរលោកទាក់ទងទៅនឹងលោក ខៀវ សំផន វិញម្ដង។ ក្នុងសក្ខីកម្មរបស់លោក នៅក្នុងលេខ E3/5511 ត្រង់ចម្លើយលេខ២៤។ លោកបានឆ្លើយថា ខ្ញុំសូមដកស្រង់៖ “ខ្ញុំបានឃើញ ខៀវ សំផន នៅក្នុងពិធីរៀបការរបស់គាត់នៅភូមិចំបក់ពណ្ណរាយ (បច្ចុប្បន្នភូមិស្ទឹង) ឃុំខ្ពបត្របែក (បច្ចុប្បន្នភូមិអូរសារាយ) ប៉ុន្តែខ្ញុំមិនបាននិយាយជាមួយគាត់ទេ។” បាទមួយទៀតនៅក្នុងឯកសារនេះដដែល គឺនៅក្នុងសំណួរចម្លើយលេខ២។ លោកបានឆ្លើយថា នៅ -- សូមដកស្រង់ “តំបន់នេះជាតំបន់បង្កើតខ្មែរក្រហម ហើយផ្ទះរបស់ តាម៉ុក ស្ថិតនៅក្នុងភូមិប្រគាប ឃុំត្រពាំងធំខាងត្បូង។ ប្រជាជនបាននិយាយថាក្នុងអំឡុងឆ្នាំ១៩៥៧ ឬឆ្នាំ១៩៥៨ ខៀវ សំផន បានមកជួប តាម៉ុក។” ខ្ញុំចង់សួរបញ្ជាក់លោកថា តើកាលៈទេសៈនេះជាកាលៈទេសៈតែមួយ ឬក៏កាលៈទេសៈពីរដាច់ដោយឡែកពីគ្នា ដែលលោកបានដឹងអំពីលោក ខៀវ សំផន?

**ឆ៖** បាទកាលៈទេសៈនេះ គឺកាលៈទេសៈពីរ។ មួយតាំងពីឆ្នាំមិនទាន់រដ្ឋប្រហារ ហ្នឹងប្រជាជន

និយាយពី ខៀវ សំផន មកជួប តាម៉ុក។ ហើយមួយទៀតដែលខ្ញុំឃើញលោក ខៀវ សំផន ហ្នឹងគឺឃើញមួយភ្លែត ដោយសារ ហើយខ្ញុំអត់ស្គាល់គាត់ទេ គឺដោយសារ យាយខឹម ប្រពន្ធតាម៉ុក ហ្នឹងចង្អុលប្រាប់ ហើយក៏ខ្ញុំអ្វូសកង់រត់ចេញមក។ តែប៉ុណ្ណឹង។ ពីរនេះខុសគ្នា។

[០៩:២៥:៥៧]

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរបញ្ជាក់ថែមទៀតថា ក្នុងឯកសារដដែលហ្នឹង ក្នុងសំណួរចម្លើយលេខ២ ដែលលោកបានបញ្ជាក់ថា មានប្រជាជននិយាយក្នុងអំឡុងឆ្នាំ១៩៥៧-៥៨ហ្នឹង។ លោកសំដៅដល់ការនិយាយជាលក្ខណៈទូទៅ ដែលឮពីមាត់មួយទៅមាត់មួយ ឬមួយក៏លោកបានជួបបុគ្គលណាម្នាក់ដែលនិយាយប្រាប់លោកជាក់លាក់ អំពីវត្តមានរបស់លោក ខៀវ សំផន មកជួបជាមួយ តាម៉ុក ហ្នឹង?

**ឆ៖** បាទ ឮប្រជាជនទូទៅនិយាយទេ និយាយហែៗតៗគ្នា អ៊ូអរអ៊ឹចឹង ព្រោះអង្គាល់ហ្នឹងវាមានរឿង។ ក្នុងសង្គមនុំងកាលហ្នឹងកំពុងច្របូកច្របល់។ អ៊ីចឹងប្រជាពលរដ្ឋសាកសួរគ្នា ប្រជុំគ្នា សួរអ៊ីចឹងទៅ។ ចេះតែនិយាយ ហើយខ្ញុំឮកាលហ្នឹង។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់កាលបរិច្ឆេទច្បាស់លាស់បានទេថា វាជាឆ្នាំ៥៧ឬឆ្នាំ៥៨ ឬមួយក៏វាជាចន្លោះដើមឆ្នាំ ចុងឆ្នាំ។ លោកអាចបញ្ជាក់បានទេ?

**ឆ៖** ខ្ញុំបាទមិនអាចបញ្ជាក់បានទេ ព្រោះយូរពេកទៅហើយ ភ្លេចបាត់អស់។ មិនសូវចាប់អារម្មណ៍ផង។

**ស៖** អម្បាញ់មិញនេះលោកបានបញ្ជាក់ថា មានបញ្ហាច្របូកច្របល់នៅក្នុងស្រុក។ តើលោកអាចបញ្ជាក់បានទេថា មានកាលៈទេសៈអ្វីដែលលោក ខៀវ សំផន ទៅជួប តាម៉ុក ហ្នឹង? លោកដឹងពីដំណើររឿង ឬក៏មានការនិយាយពីដំណើររឿងដែលនាំឲ្យមានការជួបគ្នាហ្នឹងទេ?

**ឆ៖** បាទ ធាតុពិតទៅគឺប្រជាជនខ្លះ កាលហ្នឹងខ្ញុំនៅក្មេង ប្រជាជនចាស់ៗដឹងរឿង បានតែគេភ័យអ៊ូអរ ឡើងនិយាយចុះនិយាយឡើងហ្នឹង ខ្ញុំអង្គាល់ហ្នឹង ខ្ញុំនៅក្មេងអត់សូវដឹងអីដែរ។

[០៩:២៨:៥១]

**ស៖** បាទ សូមអរគុណ។ នៅក្នុងឆ្នាំ៥៧, ៥៨ហ្នឹង តើលោកដឹងថា លោក ខៀវ សំផន មានតួនាទី ឬក៏មានឋានៈជាអ្វីដែរទេ បានជាមានការនិយាយអំពីលោក ខៀវ សំផន នៅពេលនោះ?

**ឆ៖** បើតាមខ្ញុំចាំមិនភ្លេចទេ ថាខ្ញុំនៅចាំបានថា កាលនុំងលោក ខៀវ សំផន រត់ចូលព្រៃបាត់

ទៅហើយ មិនដឹងនៅឯណា ប៉ុន្តែគេថារត់ចូលព្រៃ។

**ស៖** អ៊ីចឹងអំមិញលោកនិយាយថា លោក ខៀវ សំផន រត់ចូលព្រៃ។ បើអ៊ីចឹងវាជាការយល់ច្រឡំអំពីកាលបរិច្ឆេទ ហើយឆ្នាំនោះអាចជាឆ្នាំ៦៧, ៦៨។ ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ ព្រោះ -- ប៉ុន្តែព្រោះខ្ញុំអ៊ីចេះ ខ្ញុំទ្រង់ភ្លេចភ្លាំង ភ្លេចមុខភ្លេចក្រោយដែរ ប៉ុន្តែធាតុពិតអ៊ីចឹង។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងពេលវេលាដែលលោកបានឃើញលោក ខៀវ សំផន លោកបានឆ្លើយរួចហើយ ទាំងនៅក្នុងសក្ខីកម្មរបស់លោក ដូចខ្ញុំបានអានជូននៅក្នុងសំណួរ២៤នេះ ហើយនិងការឆ្លើយចំពោះមុខអង្គជំនុំជម្រះ។ ខ្ញុំមានសំណួរបន្ថែមទាក់ទងទៅនឹងព្រឹត្តិការណ៍នេះ ដោយលោកបានបញ្ជាក់ថា លោក ខៀវ សំផន មកដើម្បីមានពិធីរៀបការរបស់គាត់។ លោកបានបញ្ជាក់ផងដែរអំពីការជួយដឹកនំប្រពន្ធ តាម៉ុក ឈ្មោះ យាយខឹម។ ខ្ញុំចង់ដឹងថា តើលោកដឹងថាជាព្រឹត្តិការណ៍រៀបអាពាហ៍ពិពាហ៍របស់លោក ខៀវ សំផន ហ្នឹងដោយរបៀបណា?

[០៩:៣១:៣៩]

**ឆ៖** បាទ ព្រឹត្តិការណ៍នេះដែលខ្ញុំដឹងថា រៀបអាពាហ៍ពិពាហ៍របស់លោក ខៀវ សំផន នេះដោយសារ យាយខឹម ប្រាប់ទេ។ គាត់រែកនំយកមកដល់ហ្នឹង ហើយគាត់ធ្ងន់ ខ្ញុំនៅជិតហ្នឹងគាត់ស្គាត់ ក៏គាត់ឲ្យជួយយកទៅ ហើយខ្ញុំមានកង់ ដាក់កង់ហ្នឹងអូសទៅ គាត់ដើរ។ ហើយដែលដល់ទៅដល់ហ្នឹងខ្ញុំខ្លាចផង រៀបមកវិញគាត់ចង្អុលប្រាប់ថា "នោះលោក ខៀវ សំផន"។ ប៉ុន្តែឆ្ងាយប្រហែលជា៥០ម៉ែត្រឯណោះ មិនមែនបានទៅជិតអាមន្ទីរហ្នឹងទេ។

**ស៖** បាទៗ សូមអរគុណ។ ខ្ញុំសូមសួរបញ្ជាក់បន្ថែមថា លោកមានបានឮសំឡេងភ្លេង ឬក៏មានភ្ញៀវដែលគេចេញចូលក្នុងពិធីការហ្នឹងដែរទេ ពិធីរៀបអាពាហ៍ពិពាហ៍ហ្នឹងដែរទេ? ឬមួយក៏ស្ថានភាពក្នុងពេលដែលលោកមើលទៅហ្នឹងឃើញយ៉ាងដូចម្ដេចដែរ នូវទីតាំងដែលលោកបានឃើញហ្នឹង?

**ឆ៖** បាទ អត់ៗមានឃើញអីផង ព្រោះខ្ញុំទៅវាអត់ដល់មន្ទីរ ហើយបើខ្ញុំនៅឆ្ងាយក៏អត់មានឮអីហើយក៏អត់មានឃើញមនុស្ស ឃើញមើលទៅឃើញមនុស្សពីរបីនាក់ ប៉ុន្តែមិនដឹងអ្នកណា ប៉ុន្តែគ្រាន់តែយាយខឹម គាត់ចង្អុលប្រាប់ថា "នោះលោក ខៀវ សំផន" តែប៉ុណ្ណឹង ហើយខ្ញុំឮលោក ខៀវ សំផន ហ្នឹងរត់រឹងមកវិញមក។

**ស៖** បាទ សូមអរគុណ។ ក្នុងស្ថានភាពដែលលោកមើលឃើញ តើវាជាព្រឹត្តិការណ៍នៃការរៀប

អាពាហ៍ពិពាហ៍ដែរទេនៅពេលហ្នឹង ក្នុងបរិវេណដែលលោកបានមើលទៅហ្នឹង?

[០៩:៣៣:៣៦]

**ឆ៖** បាទ មិនដឹងថាៗម៉េចទេ ប៉ុន្តែមើលអត់ឃើញទេ ជិត ហើយមន្ទីរហ្នឹងមានរបងទៀត ហើយក្នុងព្រៃ ព្រៃឫស្សីហ្នឹងធំណាស់ ហើយនៅកណ្ដាលព្រៃហ្នឹង ហើយខ្ញុំនៅឆ្ងាយណាស់ មើលទៅក៏មិនដឹងថាមានអីក្នុងហ្នឹងទេ ប៉ុន្តែមើលទៅឃើញមានអគារស្លឹកហ្នឹង គ្រាន់តែមើលឃើញដំបូលហ្នឹង។ អត់មានឃើញអីក្រៅពីហ្នឹងទៀតផង ព្រោះឆ្ងាយពេកមើលមិនឃើញទេ បើបានទៅដល់ប្រហែលជាដឹង តែអត់បានទៅដល់ គេអត់ឲ្យចូល។ យាយខឹម ថា "កុំទៅ! អ្អែងទៅវិញ"។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា នៅពេលដែលលោកឃើញលោក ខៀវ សំផន ថានៅខ្ពបត្របែកហ្នឹង នៅឆ្នាំណាដែរ?

**ឆ៖** បាទ ខ្ញុំភ្លេចឆ្នាំហើយ ប៉ុន្តែដែលកាលហ្នឹងខ្ញុំទៅធ្វើទំនប់ខ្ពបត្របែកហ្នឹង ហើយខ្ញុំនៅយប់ៗឡើងខ្ញុំសម្រាន្តហ្នឹងជាមួយពលករធ្វើទំនប់ហ្នឹង ហើយខ្ញុំឃើញគាត់រែកហ្នឹងគាត់ហៅ ខ្ញុំជួយដឹកទៅ ខ្ញុំដឹកទៅ។ មិនដឹងឆ្នាំណាទេ ខ្ញុំភ្លេចហើយ ឆ្ងាយ វាច្របូកច្របល់ធ្វើទំនប់ហ្នឹងពីរបីលើក លើកមុនលើកក្រោយ បាក់ធ្វើទៀតៗ ខ្ញុំភ្លេច។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា ពេលហ្នឹងមានរដ្ឋប្រហារហើយនៅ?

**ឆ៖** បាទ មានហើយ។ កាលនោះ លន់ នល់ របបលន់ នល់ កំពុងតែទម្លាក់គ្រាប់បែក។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់រួចហើយថាលោកមិនបានឃើញលោក ខៀវ សំផន ដោយផ្ទាល់ទេ។ លោកមើលក្នុងចម្ងាយ៥០ម៉ែត្រ ហើយមិនបានឃើញមុខទេ។ ខ្ញុំចង់សួរថា លោកធ្លាប់ឃើញរូបថតរបស់លោក ខៀវ សំផន ពីមុនហ្នឹងទេ? ឧទាហរណ៍តាមរយៈសារព័ត៌មានជាដើម។

**ឆ៖** បាទ ដែលឃើញៗរូបថតក្នុងសារព័ត៌មាន ឃើញរូបថតនៅក្នុងទស្សនាវដ្ដីមានធ្លាប់ឃើញ។ កាលនៅក្មេង កាលហ្នឹងគាត់នៅក្មេង។

**ស៖** លោកនិយាយពីគាត់នៅក្មេង ឬក៏លោកនៅក្មេង លោកអាចបញ្ជាក់ឆ្នាំបានទេ?

**ប្រធានអង្គជំនុំ៖**

លោកកុំអាល់ទាន់ឆ្លើយតប!

[០៩:៣៧:០៤]

**លោក វៀល សន៖**

**ឆ៖** បាទ ដែលខ្ញុំឃើញរូបថតគាត់ហ្នឹង កាលហ្នឹងគាត់នៅក្មេងដែរ ហើយខ្ញុំរឹតតែក្មេងទៀត អង្គាល់នុំង មិនទាន់នឹងមានគ្រួសារទេ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរលោកទាក់ទងទៅនឹងឯកសារ E319.1.21 ត្រង់សំណួរចម្លើយលេខ៥០។ ទាក់ទងទៅនឹងចៅអធិការវត្តមួយអង្គ ព្រះនាម តាអ៊ិច។ ខ្ញុំសូមអានជូនចម្លើយរបស់លោក សូមដកស្រង់៖ "តាអ៊ិច ជាចៅអធិការវត្តបានតវ៉ាជាមួយនឹងខ្មែរក្រហម ហើយគាត់បានទូងស្គរឱ្យប្រជាជនមកប្រឆាំងនឹងពួកខ្មែរក្រហម ប៉ុន្តែពេលនោះពុំមានប្រជាជនណាហ៊ានមកនោះទេ។ ខ្មែរក្រហមបានវាយគាត់ពីរបីព្រនង់ប៉ុណ្ណោះ។" សូមបញ្ចប់ការដកស្រង់។ ខ្ញុំចង់សួរលោកថា តើលោកដឹងដោយរបៀបណាអំពីការទូងស្គរ និងការវាយទៅលើព្រះសង្ឃនេះ?

**ឆ៖** បាទ កាលនោះ ខ្ញុំនៅកន្លែងហ្នឹងដែរ ជិតហ្នឹង ព្រោះមានលោកពីភ្នំពេញទៅនៅហ្នឹង ជាលោកគ្រូ គ្រូមេកុដ២៤ នៅវត្តលង្កាហ្នឹងខ្ញុំធ្លាប់នៅជាមួយលោក ខ្ញុំទៅដែរ ទៅមើលលោក យកចង្ហាន់យកអីទៅប្រគេនលោក។ ប៉ុន្តែក្រោយហ្នឹងគេដេញខ្ញុំចេញទៅ ខ្ញុំទៅផ្ទះទៅ អត់ហ៊ាននៅ តែកន្លែងណាគេដេញ អត់ហ៊ានទៅទេ។

**ស៖** លោកធ្វើអីដែរនៅពេលនុំង?

**ឆ៖** បាទ--

[០៩:៣៩:៥៤]

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយតបសាក្សី! ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិនណា។

**លោក រៀល សន៖**

**ឆ៖** បាទ កាលនោះនៅផ្ទះ ទើបថ្ងៃផ្សឹកលោកហ្នឹង ដូចទើបធ្វើរដ្ឋប្រហារហើយប៉ុន្មានខែទេ ភ្លេចអស់ហើយ ខ្ញុំភ្លេចអស់ហើយវាយូរពេកហើយ។ ហើយអត់ដែលបានសូវគិតផងរឿងអស់ហ្នឹង។ គិតតែពីរឿងធ្វើ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំចង់សួរលោកបន្ថែមថា តើអ្នកណាខ្លះនៅជាមួយលោកនៅពេលនោះ?

**ឆ៖** បាទ ភ្លេចទៅហើយ ប៉ុន្តែមានអ្នកនៅជាមួយនៅហ្នឹង ឈរជាមួយគ្នាហ្នឹងមានអ្នកបើក

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឡានដឹកខោអាវមកម្នាក់ ក្មេងៗតូច ហើយនិងម្នាក់ទៀតចាស់ ដែលយកដំបងវ៉ៃលោកហ្នឹង។ មុនដំបូងថាបែបវ៉ៃលេង ប៉ុន្តែមិនវ៉ៃលេងវ៉ៃខ្លាំង ខ្ញុំសួរលោក លោកថាឈឺ។

**ស៖** លោកស្គាល់អ្នកដែលវ៉ៃហ្នឹងទេ?

**ឆ៖** បាទ មិនស្គាល់ទេ គាត់ហ្នឹងចាស់ហើយ ក្បាលទំពែក។ កាលនុំងខ្ញុំមិនដែលឃើញមានឡានផង ទើបនឹងឃើញឡានដឹកខោអាវហ្នឹងមក ឡានហ្ស៊ីបមួយ។

**ស៖** បាទ សូមអរគុណ។ លោកចាំថា ឆ្នាំណាទេពេលហ្នឹង?

[០៩:៤១:២៦]

**ឆ៖** បាទ ធាតុពិតមិនចាំទេ រឿងថ្ងៃខែឆ្នាំហ្នឹង វាយូរពេកៗហើយក៏អាព្រឹត្តិការណ៍ដែលកើតមានហ្នឹង គឺខ្ញុំមិនដែលបានគិតផងហ្នឹង។ អត់ដែលបានគិត ដល់ពេលអានេះ ស្វែងរកការពិតហ្នឹងទៅហ្នឹង សួរទៅ ចេះតែរកនឹកឃើញអ៊ីចឹង ហើយចេះតែប្រាប់មក ដើម្បីស្វែងរកការពិតហ្នឹងឲ្យវាឃើញច្បាស់។

**ស៖** បាទ លោកបានឆ្លើយថា លោកនៅកន្លែងវត្តនៅពេលហ្នឹង។ តើលោកទៅទីវត្តហ្នឹងដើម្បីអ្វីដែរ? ធ្វើអ្វីដែរនៅពេលហ្នឹង?

**ឆ៖** បាទ ខ្ញុំជម្រាបតុលាការអំមិញហើយថា ខ្ញុំយកចង្ហាន់ទៅប្រគេនលោកគ្រូខ្ញុំ គឺលោកគ្រូមេកុដិលេខ២៤ នៅវត្តលង្កា អង្កាល់ខ្ញុំនៅក្មេង ខ្ញុំនៅជាមួយលោក ហើយដឹងថាលោកគេយកមកហ្នឹង ខ្ញុំក៏ទៅ ជួបជាមួយលោក យកចង្ហាន់លោកទៅ ហើយឃើញគេដឹកទៅ ហើយខ្ញុំត្រឡប់ទៅផ្ទះវិញទៅ។

**ស៖** មានមនុស្សផ្សេងទៀតច្រើនគ្នាទេ ដែលនៅក្នុងបរិវេណវត្តហ្នឹង ក្រៅពីអ្នកបើកឡានម្នាក់ ហើយនិងបុរសចំណាស់ម្នាក់ដែលលោកមានប្រសាសន៍ហ្នឹង?

**ឆ៖** បាទ គ្មានទេ។ មានតែអ្នកដាំបាយៗបីបួនខ្ទះ ឆ្នាំងខ្ទះបួនប្រាំ ដាំបាយសម្រាប់លោកឆាន់ហ្នឹង ព្រោះពេលព្រឹក។ ក្រៅពីហ្នឹងគ្មានទេ មានតែពីរបីនាក់ ដាំបាយហ្នឹង តែពីរនាក់ទេ ពីរបីបួនខ្ទះ។

[០៩:៤៣:៤៩]

**ស៖** បាទ មានលោកច្រើនអង្គទេនៅ គង់នៅវត្តហ្នឹង?

**ឆ៖** បាទ មិនមែនលោកនៅគង់ហ្នឹងវត្តហ្នឹងតែម្តងទេ គឺលោកជម្លៀសមកពីភ្នំពេញ និងពីកន្លែងផ្សេងៗមក ប្រហែលជាជាង១០០អង្គ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរលោកទាក់ទងទៅនឹង តាម៉ុក លោកមានប្រសាសន៍នៅក្នុង

ឯកសារដដែលអម្បាញ់មិញហ្នឹង ត្រង់សំណួរ-ចម្លើយលេខ៦៣។ លោកបានបញ្ជាក់ថា លោកធ្លាប់បានជួបជាមួយ តាម៉ុក ដើម្បីទទួលការណែនាំធ្វើថ្នាំ។ ហើយកាលពីថ្ងៃទី១៧ ខែ៣ កន្លងទៅនេះលោកបានឆ្លើយនៅម៉ោងប្រហែលនៅម៉ោង ០២:២៥ នាទីរសៀលថា លោកនៅពេលដែលឃើញជួបជាមួយ តាម៉ុក លោកតែងខ្លាចហើយរត់ពួន ហើយអ្នកដទៃទៀតក៏ដូចគ្នាដែរ។ ខ្ញុំចង់ឱ្យលោកបញ្ជាក់អំពី តាម៉ុក នៅពេលដែលលោកជួប ទទួលការណែនាំពីរឿងធ្វើថ្នាំ តើវាមានលក្ខណៈខុសគ្នាយ៉ាងម៉េចចំពោះពាក្យសម្តី តាម៉ុក ដែលលោកបានជួបនិយាយផ្ទាល់ជាមួយនឹងការនិយាយ ឬក៏ការភ័យខ្លាចរបស់អ្នកផ្សេងទៀតនោះ?

**ឆ៖** បាទ ពិតណាស់ តាម៉ុក បើគាត់មកដល់ឃើញយើងហើយ បើគាត់មិនហៅ ទៅជិតគាត់មិនបានទេ គាត់មិនឱ្យទៅជិតគាត់ទេ។ ដល់បើគាត់ហៅទៅជួបជាមួយគាត់ អាហ្នឹងដល់ទៅជួបជាមួយគាត់។ ប្រជាពលរដ្ឋក៏អ៊ីចឹងដែរ បើឃើញហើយថា អានេះអានោះ អ្នែងមកនេះមក អាហ្នឹងបាន១។ ហើយបើឃើញមកអីគិតគូរថា រត់ទៅអ៊ីចេះអ៊ីចុះអីអត់បានទេ ហ្នឹង តាម៉ុក។

[០៩:៤៦:៤២]

**ស៖** លោកធ្លាប់ដឹង ឬក៏ឮ ឬក៏ធ្លាប់ទទួលការបញ្ជាផ្សេងទៀត ទាក់ទងទៅនឹងបញ្ជារបស់ តាម៉ុក ដែរទេ?

**ឆ៖** បាទ មាន១តើ។ ថ្ងៃមួយ ខ្ញុំអស់មេថ្នាំប្រើប្រាស់ ហើយខ្ញុំឃើញគាត់មក ខ្ញុំជួបគាត់នៅតាមផ្លូវ សួរ ប្រាប់គាត់ថា អស់មេថ្នាំ ហើយខ្ញុំថា ត្រូវការមេថ្នាំ អង្កាល់ហ្នឹងត្រូវការមេថ្នាំកង់ហ្វូ មានប្រជាពលរដ្ឋនៅកងទី៣ពុល។ អ៊ីចឹង គាត់ថា៖ “អ្នែងធ្លាប់ទិញ ម៉េចមិនទៅទិញ”។ ខ្ញុំថា៖ “អត់មានលុយ១ទេឥឡូវ មានចាយលុយឯណា”។ ហើយគាត់សរសេរសំបុត្រមួយ ឱ្យខ្ញុំទៅស្រុក៥៥ ភ្លាមហ្នឹងសរសេរពីរបីម៉ាត់ហ្នឹង គាត់សរសេរពីរបីម៉ាត់នៅឡានហ្ស៊ីបគាត់។ “ឱ្យទៅស្រុក៥៥ ឱ្យទៅជួបជាមួយអាចុង ហើយអ្នែងសុំលុយគេទៅ”។ ហើយខ្ញុំទៅ អាហ្នឹងចុងក្រោយហើយ។ ហើយខ្ញុំទៅ យកសំបុត្រហ្នឹងទៅ ទៅប្រាប់ តាចុង១ ហ្នឹងគាត់ឱ្យជ្រូកបីបួនប្រាំក្បាលអ៊ីចឹងទៅ ដឹកយកទៅដូរជាមួយយួនជាមួយវៀតណាម ហើយត្រឡប់មកវិញមក។ ហ្នឹងរឿង តាម៉ុក។

**ស៖** បាទ សូមអរគុណ។ លោកធ្លាប់បានទទួលបញ្ជាទាក់ទងទៅនឹងបញ្ហាសន្តិសុខ បញ្ជាចាប់ខ្លួន ឬបញ្ជាអីដែរទេ ទាក់ទងទៅនឹង តាម៉ុក?

**ឆ៖** បាទ គ្មានសោះតែម្តង ដើម្បី -- ជាមួយ តាម៉ុក ពីការចាប់ខ្លួន ពីអីអត់មាន គឺគ្មាន។

[០៩:៤៨:៥៧]

**ស៖** ចុះទាក់ទងទៅនឹងបទបញ្ជាផ្សេងទៀត ដែល តាម៉ុក បញ្ជាទៅអ្នកផ្សេង លោកបានដឹង ឬក៏បានឮទាក់ទងទៅនឹងបញ្ជាពីអ្នកផ្សេងទៀតទេ?

**ឆ៖** បាទ ខ្ញុំស្ដាប់មិនសូវបានសំណួរហ្នឹង។ សួរម្ដងទៀត។

**ស៖** ខ្ញុំចង់សួរថា លោកបានឮ តាម៉ុក បញ្ជាទៅអ្នកផ្សេងទៀតជាកម្មាភិបាលទាក់ទងទៅនឹងការចាប់ចង ការធ្វើទារុណកម្មអីជាដើម។ លោកមានធ្លាប់ឮពីការបញ្ជាដែលពាក់ព័ន្ធនឹង តាម៉ុក នេះដែរទេ?

**ឆ៖** បាទ ធាតុពិតខ្ញុំមិនដែលឮទេ ព្រោះបើមានបញ្ជាពី តាម៉ុក ទៅលើរឿងចាប់ចងអីមួយនោះគឺមិនមែនបញ្ជានៅមុខខ្ញុំអត់ទេ បញ្ជានៅកន្លែងស្ងាត់ៗ អីចឹង។ ដល់កន្លែងស្ងាត់បានគាត់ធ្វើ អារឿងចាប់ចងអីហ្នឹង គឺអត់ទេ ខ្ញុំមិនដែលបាននៅក្បែរចូលរួមគឺអត់ទេ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវី អាកទួរ វែកគែន!

[០៩:៥០:៣១]

**លោក អាកទួរ វែកគែន៖**

បាទសូមអរគុណ លោកប្រធាន។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** បាទ លោកសាក្សី ខ្ញុំសូមសួរចំណុចមួយទាក់ទងទៅនឹងលោក ខៀវ សំផន។ អម្បាញ់-មិញលោកបាននិយាយថា លោកបានឃើញគាត់ពីរដង។ ខ្ញុំកត់សម្គាល់ឃើញថា នៅពេលដែលគេសម្ភាសលោក គឺអ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានោះ គេសួរលោកនោះ លោកបាននិយាយថា បានជួបគាត់ជាលើកទី៣ គឺនៅពេលមួយដែលគាត់ត្រូវបានគេសម្រាតសម្លៀកបំពាក់ដោយនគរបាលនៅចំកណ្ដាលផ្សារ។ តើលោកចាំថាលោកបាននិយាយអីចឹងទៅមជ្ឈមណ្ឌលឯកសារកម្ពុជា? ហើយលោកបានឃើញនៅផ្ទាល់ភ្នែកដែរឬទេ? លោកមានវត្តមាននៅទីនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំឃើញកាលហ្នឹងខ្ញុំនៅរៀនភ្នំពេញ ខ្ញុំនៅតូច ហើយខ្ញុំដើរទៅយកស្រាក់នៅផ្ទះ

ក្រោយមកហ្នឹងឯកឧត្តម សារិន ឆាក ហ្នឹងខ្ញុំទៅយកស្រាក់រាល់ថ្ងៃ។ អ៊ីចឹងទៅឃើញអ្នកស៊ីក្លូអីរត់ឈ្លូនរនៅម្តុំខាងលិចវាំងឆ្ងាយ អង្កាល់ហ្នឹងភ្នំពេញវានៅតូចៗ។ ហើយសួរគេទៅ គេថាមើលទៅ ខៀវ សំផន គេធ្វើបាបអីអ៊ីចឹងទៅ។ ហ្នឹងបានតែប៉ុណ្ណឹង ខ្ញុំគ្រាន់តែឮថាអ៊ីចឹង ខ្ញុំទៅទៀតទៅៗយកស្រាក់ឃើញតើអង្កាល់ហ្នឹង ឃើញប៉ុន្តែហ្នឹងក៏ឃើញឆ្ងាយដែរ មិនឃើញជិតទេ ព្រោះមនុស្សច្រើនណាស់ អ្នកស៊ីក្លូវាប់រយ។ បាទតែប៉ុណ្ណឹងទេ។

**ស៖** អ៊ីចឹងគេនិយាយប្រាប់លោកទេ លោកមិនបានឃើញដោយផ្ទាល់ភ្នែកទេ អ៊ីចឹងមែនទេ?

[០៩:៥២:៤១]

**ឆ៖** បាទ ឃើញផ្ទាល់ភ្នែកដែរ ប៉ុន្តែឃើញពីឆ្ងាយដូចពីត្រឹមជញ្ជាំងនោះទៅត្រឹមជញ្ជាំងនោះ មនុស្សវាច្រើនអ៊ូអរ យើងនៅឈរមើលក្រោយគេ ឃើញដឹងស្លៀកក្រមាទៅហើយ កាលនោះ មុនហ្នឹងបែបអត់មានក្រមាស្លៀកទេ ព្រោះអ្នកស៊ីក្លូអាខ្លះគ្រវាត់ក្រមាទៅ អាខ្លះគ្រវាត់អាវទៅឲ្យ ខោទៅឲ្យ។ ហើយព្រឹត្តិការណ៍ហ្នឹងមិនដឹងម៉េចទេ កាលហ្នឹងខ្ញុំនៅតូចដែរ យូរហើយ យូរពេកហើយ។ ដឹងប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ បាទ លោកបាននិយាយជាច្រើនដងប៉ុន្មានថ្ងៃកន្លងមកនេះ គឺថាៗមានមនុស្សមួយចំនួនដែលនៅជុំវិញលោកសុទ្ធតែជាអ្នកអត់បានរៀនសូត្រ គឺអនក្ខរជនទៀតផង ហើយមិនមានបទពិសោធន៍អ្វីទាំងអស់។ អ៊ីចឹងបើតាមលោកយល់ឃើញ តើមានមូលហេតុអ្វីដែលគេផ្តល់ការងារឲ្យអ្នកដែលយើងមើលទៅមិនទំនងជាអាចធ្វើទៅបាន អត់មានសមត្ថភាព? តើ<លោកពន្យល់យ៉ាងម៉េចចំពោះការពិតដែលថា>អ្នកធ្វើការជុំវិញលោកនោះ ដែលសុទ្ធតែជាមនុស្សដែលគ្មានសមត្ថភាពផ្នែកបញ្ហា<មកទទួលការងារដែលគេបានដាក់ឲ្យពួកគេនោះទេ>?ខ្ញុំសួរតែចំពោះលោកផ្ទាល់ លោកយល់យ៉ាងម៉េចដែរ កាលសម័យនោះម៉េចក៏គេឲ្យអ្នកមិនចេះអក្សរអីមកជួយធ្វើការលោកទៅវិញ?

**ឆ៖** បាទ កាលនុ៎ងខ្ញុំបាទសួរគេដែរ ហេតុអីក៏ឲ្យអ្នកមិនចេះអក្សរ អត់ចេះអីសោះមកអ៊ីចឹង? គេស្តីឲ្យខ្ញុំវិញថា ឲ្យយកទៅឲ្យបង្ហាត់បង្រៀនហ្នឹងហើយ ឲ្យចេះអក្សរឲ្យចេះអីគ្រប់សព្វអីអ៊ីចឹងទៅ ដោយឲ្យខ្ញុំអ្នកបង្រៀនទៅវិញអ៊ីចឹង។ គេថាអ៊ីចឹង។

[០៩:៥៤:៥៧]

**ស៖** អ៊ីចឹង បានន័យថាក្រោយមកហ្នឹងលោកព្យាយាមខិតខំបណ្តុះបណ្តាលពួកគាត់ហ្នឹង អប់រំពួកគាត់ហ្នឹង អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** បាទ លោកសាក្សីសូមឆ្លើយម្តងទៀត ពីព្រោះអត់មានការបកប្រែចេញទៅជាភាសាបារាំងទេ។ ខ្ញុំស្តាប់អត់ឮចម្លើយបាទ។

**ប្រធានអង្គជំនុំ៖**

ឆ្លើយ! សាក្សីអំមិញមិនទាន់ឆ្លើយដោយសារក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការ។ លោកឆ្លើយអំមិញនេះ ឥឡូវចាំឆ្លើយតបនឹងសំណួរអំមិញនេះ។

**លោក វៀល សន៖**

**ឆ៖** ខ្ញុំៗបាទភ្លេចសំណួរហ្នឹងហើយ សួរម្តងទៀត។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** អម្បាញ់មិញនេះ ខ្ញុំសួរលោក<សាមញ្ញទេ>ថា តើលោក<>ខំព្យាយាមបណ្តុះបណ្តាលបុគ្គលិករបស់លោក ដើម្បីជួយបំពេញវិជ្ជាដល់គាត់<។ តើលោកខ្លួនឯងផ្ទាល់>ហ្នឹងព្យាយាមអប់រំអ្នកនៅធ្វើការជាមួយលោក<ដូចដែលគេបានណែនាំដល់លោកឬទេ>?

[០៩:៥៦:២៦]

**ឆ៖** បាទ ខ្ញុំបាទប្រឹងប្រែងអប់រំទាំងគ្រប់ផ្នែក ទាំងផ្នែកអក្សរសាស្ត្រ ទាំងផ្នែកព្យាបាលជំងឺ ទាំងផ្នែកចាក់ថ្នាំអី គឺខ្ញុំបាទជួយអប់រំណែនាំរាល់តែថ្ងៃ តែពេលធ្វើការគឺខ្ញុំទៅហើយបើខ្ញុំនៅកន្លែងហើយបើខ្ញុំមិននៅកន្លែងអាហ្នឹងមាននារីៗ នារីប្រធានៗហ្នឹងមិនចេះចាក់ថ្នាំ ប៉ុន្តែវាចេះដើរមើលដែរ វាខ្លាចប៉ះពាល់អីដល់អ្នកជំងឺ និងពេទ្យហ្នឹង។ ហ្នឹងនៅកន្លែងនារី ឯបើកន្លែងបុរសវិញគឺមិនមានបញ្ហាអី។

**ស៖** អ៊ីចឹង ថាពេលវេលាដែលកន្លងទៅ ដោយសារតែលោកបណ្តុះ-- ថាលោកបណ្តុះបណ្តាលគាត់ អប់រំគាត់រហូតហ្នឹង អ៊ីចឹងគឺថាបានន័យថា កាន់តែប្រសើរទៅ ពេលវេលាកាន់តែកន្លងទៅមុខសមត្ថភាពពួកគាត់កាន់តែកើនឡើង អ៊ីចឹងមែនទេ?

**ឆ៖** បាទ សមត្ថភាពគាត់គ្រាន់តែកើនឡើង។

**ស៖** ឥឡូវ ខ្ញុំសូមឲ្យលោកនិយាយអំពីចំណុចមួយដែលលោកបានលើកឡើងនៅចំពោះមុខអ្នកស៊ើបសួរលោកដែលមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា គឺនិយាយអំពីការទំនាក់ទំនង ឬក៏ការដោះដូរជាមួយនឹងវៀតណាមដែលលោកបានធ្វើ។ លោកបាននិយាយនៅក្នុងសវនាការនេះកន្លងមកហើយ គឺការដោះដូរគ្នាដើម្បីទិញថ្នាំជាដើមនោះ ឬក៏ផលិតផលដែលលោកយកមកប្រើដើម្បីផលិតថ្នាំជាដើម។ អ៊ីចឹងខ្ញុំចង់ដឹង សូមឲ្យលោកជួយបំភ្លឺ ថាតើសត្វ ឬក៏វត្ថុដែលលោកដោះដូរជាមួយវៀតណាមដើម្បីឲ្យ

បានផលិតផលទាំងអស់នោះ តើលោកធ្វើយ៉ាងដូចម្ដេច?

[០៩:៥៨:៥៥]

**ឆ៖** បាទ អង្កាល់នុ៎ងខ្ញុំស៊ុំ តាម៉ុក ទៅ គាត់សរសេរសំបុត្រមួយឲ្យទៅយកជ្រូកនៅស្រុក៥៥ គឺកន្លែងប្អូនគាត់គឺឈ្មោះ ចុង – តាចុង។ អ៊ីចឹង ដល់កាលណាគាត់ឲ្យទៅយកជ្រូក ខ្ញុំទៅយកជ្រូកបានជ្រូកប្អូនអ៊ីចឹងទៅ ហើយកាលនុ៎ងវានៅជិតព្រំប្រទល់ដែរ ជិតនេះ ខ្ញុំដេញជ្រូកហ្នឹងកណ្ដាលវាលទៅ ទៅដល់អង្គរបុរីហ្នឹង។ ដេញជ្រូកដាក់ក្នុងទូក ហើយជិះទូកទៅបាក់ដៃទៅ។

**ស៖** តើការដោះដូរហ្នឹងកើតមានឡើងក្នុងអំឡុងរបបខ្មែរក្រហម ចន្លោះឆ្នាំ១៩៧៥-៧៩ហ្នឹងមានដែរ ឬក៏យ៉ាងម៉េច?

**ឆ៖** ការដោះដូរនេះ មានជាហូរហែមក ប៉ុន្តែរហូតដល់លែងទំនាក់ទំនងគ្នាបាន វៀតណាមអត់ -- វាលែងទំនាក់ទំនងគ្នាជាមួយយើងបាន ក៏ផុតទៅ វៀតណាមវាអត់មានទំនាក់ទំនង។

**ស៖** នៅពេលដែលលោកនិយាយគ្នាជាមួយអ្នកស៊ើបនៅមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបាននិយាយអំពីការទិញនាឡិកា<សម្រាប់>កម្មាភិបាលនៅក្នុងតំបន់របស់លោកនោះ។ លោកចាំទេ ថាលោកបាននិយាយអំពីរឿងកំប៉ិកកំប៉ុកនេះជាមួយនឹងអ្នកស៊ើបអង្កេតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា រឿងទិញនាឡិកា?

[១០:០១:០០]

**ឆ៖** បាទ រឿងទិញនាឡិកា គឺដូចជាខ្ញុំមិនដែលទិញនាឡិកាឲ្យកម្មាភិបាលទេ ប៉ុន្តែបើចរិតខ្ញុំមិនចេះពាក់នាឡិកា មិនហ៊ានពាក់នាឡិកា ខ្មាសគេ។ អ៊ីចឹងបើកាលណា ដូចថា តាម៉ុក អីគាត់ឲ្យមកតាមរយៈស្រុកអី ខ្ញុំយកមកៗដល់ឲ្យទៅអ្នកនេះ ឲ្យទៅអ្នកនោះ នាឡិកា ហ្នឹងរឿងនាឡិកា។ ហើយនាឡិកាដែល ខ្ញុំមិនដែលទិញនាឡិកាឲ្យកម្មាភិបាលទេ ប៉ុន្តែនាឡិកាជួនកាលអីនៅកន្លែងពាណិជ្ជកម្មៗស្រុកហ្នឹង ឃើញអាអាវជជុះមកមួយបាវពីរបាវហ្នឹង ជួនកាលជជុះទៅបានដុល្លារ១០០, ២០០ គេហែកចោលទៅ។ ជួនកាលបាននាឡិកាម៉ាកវ៉ាដូ ម៉ាកស៊ីទីហ្សែនអ៊ីចឹងទៅ ឲ្យទៅកម្មាភិបាលៗ ក្នុងភូមិ ឃុំអីហ្នឹង ខ្ញុំអត់ចេះពាក់នាឡិកានឹងគេ។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមនិយាយរំឭកលោក គឺមានពាក្យពេចន៍ដែលលោកប្រើនៅក្នុងអត្ថបទនេះ។ អ៊ីចឹងខ្ញុំសូមអានឯកសារ D313/1.2.409, ERN ជាភាសាបារាំងគឺ 00808632, ERN ជាភាសាខ្មែរ 00418835, ERN ជាភាសាអង់គ្លេសគឺ 00729051។ បាទ នេះគឺជាការពិភាក្សា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

របស់លោកកាលពី១៤ឆ្នាំមុន ជាមួយនឹងអ្នកស៊ើបសួររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ បាទ លោកឆ្លើយដូចតទៅនេះ៖ “ខ្ញុំចេះធ្វើវីតាមីនសេ ពីព្រោះខ្ញុំបានទទួលការបណ្តុះបណ្តាលនៅក្នុងវិស័យនេះ ក៏ប៉ុន្តែខ្ញុំធ្វើតិចតួចទេ តាមការណែនាំរបស់ថ្នាក់លើ ខ្ញុំទិញធាតុផ្សំមកពីប្រទេសវៀតណាម។ គឺនៅឆ្នាំ៧៥ឬ?” លោកឆ្លើយថា៖ “បាទ។ សំណួរ៖ ចុះទិញម៉េចបើដឹងថា អំចាក់លុយចោលនោះ? ចម្លើយ៖ <ខ្ញុំប្រើ>មាស <ដែលផ្តល់ឲ្យដោយ> តាម៉ុក <និងមេដឹកនាំ>តំបន់ហ្នឹង<។ រាល់ការទិញម្តងៗ ខ្ញុំយកមាសទៅប្រទេសវៀតណាម>បួន ឬប្រាំគីឡូ<>។ ហើយថា បងប្អូនដែលនៅក្នុងភូមិទាំងនេះ គ្រាន់តែដឹងថានៅ -- ទៅស្រុកយួន អាខ្លះផ្ញើ មួយដំឡឹងទៅទិញ <ដើម្បីទិញ>នាឡិកាពីរបី<បួន>អីចឹងដែរ <រាល់ពេលគេដឹងថាខ្ញុំទៅវៀតណាម។> សំណួរ៖ គេពាក់នាឡិកាអីចឹង គេអត់ដកហូតទេឬ? ចម្លើយ៖ ចុះដកហូតអី ព្រោះថាសុទ្ធតែជាកម្មាភិបាល។ សំណួរ៖ តើនៅឆ្នាំណាលោកទៅវៀតណាមដើម្បីដូរមាស? ចម្លើយ៖ គឺឆ្នាំ១៩៧៥ និង ៧៦។” សូមបញ្ចប់ការដកស្រង់។ បាទ នេះគឺជាមូលហេតុដែលធ្វើឲ្យខ្ញុំចោទសំណួរមួយអម្បាញ់មិញទៅលោកនេះ ចង់សួរថាតើលោកដឹងដែរ -- នៅចាំទេថាគេបានឲ្យមាសលោកយកទៅដូរអីវ៉ែអីវ៉ាន់ពីប្រទេសវៀតណាមក?

[១០:០៤:៤៧]

**ឆ៖** បាទ ខ្ញុំបាទដឹង ប៉ុន្តែចាំមិនអស់ មិនដឹងប៉ុន្មានដងគឺមិនចាំ ហើយទៅជាចំនួនប៉ុន្មានគឺអត់ចាំទេ ភ្លេចបាត់អស់។

**ស៖** តើលោកដឹងថា មាសហ្នឹងបានមកពីណាដែរទេ មាសដែលលោកយកទៅដូរនាឡិកានៅវៀតណាមហ្នឹង?

**ឆ៖** បាទ ខ្ញុំបាទមិនដឹងទេ ប៉ុន្តែមាសហ្នឹងបើរៀបទៅ ទៅដល់មន្ទីរស្រុក ពាណិជ្ជកម្មស្រុកហ្នឹង គេឲ្យហើយ។ គេមិនបានថ្លឹងបានអី វេចកញ្ចប់ឲ្យ យកជិះកង់ទៅ ទៅទិញ។

**ស៖** តើការដោះដូរគ្នានេះ មានការអនុញ្ញាតទេ? ហើយគេចាត់ទុកថាមិនជាការអាក្រក់ទេ ឬក៏យ៉ាងណានៅក្រោមរបបខ្មែរក្រហមនេះ?

**ឆ៖** ខ្ញុំបាទ កាលនោះមិនដឹងដែរ ប៉ុន្តែដោះដូរនេះ ដែលហ៊ានទៅដោះដូរដោយសារតាមរយៈអីចឹង។ ប្រាប់ស្រុក ប្រាប់ស្រុកយើងផង និងប្រាប់ស្រុកនៅព្រំប្រទល់ផង បានហ៊ានដោះដូរ។

[១០:០៦:៥៤]

**ស៖** ហើយអីចឹងថា ប្រថុយនឹងគ្រោះថ្នាក់នៅពេលដែលលោកទៅដោះដូរយ៉ាងនេះ ឬក៏យ៉ាង

ម៉េច?

**ឆ៖** បាទ កាលនោះប្រថុយនឹងគ្រោះថ្នាក់ណាស់ ទៅដល់កន្លែងដោះដូរហ្នឹងគ្រោះថ្នាក់។ កាលណាយើងឲ្យវា យួនវាយកអីវ៉ាន់មកដោះដូរជាមួយយើង វាយកមកលាក់ វាខ្លាចប៉ូលិស ខ្លាចរដ្ឋអំណាចវាដែរ។ ហើយយើងទៅពីនេះ យើងអត់មានខ្លាចរដ្ឋអំណាចយើង ព្រោះយើងមានសិទ្ធិកន្លែងយើង ប៉ុន្តែខ្លាចវា។ អ៊ីចឹងដោះដូររបៀបដោះដូរ ឧទាហរណ៍ថាឥឡូវ នេះខ្ញុំយកជ្រូកមកបួនក្បាលហើយ មើលទៅប៉ុណ្ណឹង។ ហើយអីវ៉ាន់ហ្នឹង ខ្ញុំកុម្មង់ហ្នឹងគ្រប់ឬមិនគ្រប់ ឧទាហរណ៍ថា យកក្រណាត់យកមកធ្វើអង្រឹងហ្នឹង១០កី យកខ្សែអង្រឹងហ្នឹងប៉ុន្មានរយអីអ៊ីចឹងទៅ គិតគូរទៅ ទូទាត់ទៅ អាអ្នកដែលវាដោះដូរជាមួយយើងហ្នឹង វាប្រាប់ថា វាគ្រប់គ្រាន់ទៅ ម្តងថាគ្រប់គ្រាន់ ដល់បើអត់គ្រប់គ្រាន់ វាថានៅខ្វះខាតទៀត ថ្ងៃក្រោយចាំយកក៏បានដែរ អ៊ីចឹង។

**ស៖** បាទ សូមអរគុណដែលបាននិយាយបញ្ជាក់យ៉ាងដូច្នេះ ប៉ុន្តែអ្វីដែលខ្ញុំចង់បាននោះ ចង់ដឹងនោះ គឺថាតើលោកប្រថុយនឹងគ្រោះថ្នាក់ដែរឬទេ? ព្រោះថានៅក្នុងតំបន់ដែលលោករស់នៅនោះ តើវាអាចជាការគ្រោះថ្នាក់ដែរឬទេ ព្រោះថាគេលុបបំបាត់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឯកជន ដាក់រួមទាំងអស់ហើយ? គឺថាក្នុងបរិបទបែបនេះៗ តើគេអាចទទួលយកបានទេដែលលោកយកមាសទៅដោះដូរជាមួយនាឡិកា<អ៊ីចឹង>? អ៊ីចឹងថាតើការធ្វើបែបនេះអាចប្រថុយប្រថាននឹងគ្រោះថ្នាក់ដែរ ឬទេ ចំពោះអាជ្ញាធរខ្មែរក្រហមនៅសម័យនោះ?

**ឆ៖** បាទ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១០:០៩:២១]

**លោក ឌេល លីសាក់៖**

<អរគុណលោកប្រធាន។ ខ្ញុំគិតថា នេះជាសំណួរច្រំដែល។ គាត់ទើបតែសួរ ហើយសាក្សីបានឆ្លើយថា តាម៉ុក អ្នកបញ្ជា។ អ៊ីចឹង ខ្ញុំមិនប្រាកដថាហេតុអីក៏មេធាវីគាត់សួរសំណួរដដែលហ្នឹងទៀត។>

*(មានបញ្ហាបច្ចេកទេស)*

[១០:១១:៣៨]

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១១ នាទី ដល់ម៉ោង ១០:៣៦ នាទី)*

[១០:៣៦:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅលោកមេធាវី អាកទួរ វែកគែន អង្គជំនុំជម្រះសូមជម្រាបថាសាក្សីបម្រុងដែលមានរហស្សនាម 2-TCW-822 មានបញ្ហាសុខភាពធ្ងន់ធ្ងរ សម្ពាធឈាមឡើងខ្ពស់។ ហើយខាងគ្រូពេទ្យផ្តល់អនុសាសន៍ថា គាត់មិនអាចចូលរួមផ្តល់សក្ខីកម្មបានទេ គាត់ត្រូវសម្រាកព្យាបាលមួយរយៈពេល។

ហើយដូច្នេះ អង្គជំនុំជម្រះដោយសារបញ្ហានេះ គាត់មានបញ្ហាសុខភាពបែបនេះ អង្គជំនុំជម្រះសម្រេចមិនស្តាប់សក្ខីកម្មសាក្សីរូបនេះនៅក្នុងថ្ងៃនេះ ក៏ដូចជានៅសប្តាហ៍ក្រោយបានទេ។ ហើយការស្តាប់សក្ខីកម្មរបស់សាក្សីដែលមានរហស្សនាម 2-TCW-822 អង្គជំនុំជម្រះនឹងជម្រាបជូនដំណឹងដល់ភាគី និងសាក្សីនាពេលខាងមុខ នៅពេលសមស្របនាពេលខាងមុខ។

ហើយអង្គជំនុំជម្រះបង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីបម្រុង TCW-822 ត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដើម្បីព្យាបាលគាត់ចុះ ទៅវាប់ឥឡូវនេះណា។ អនុញ្ញាតឱ្យគាត់ទៅចុះ។ បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន គឺ លោកមេធាវីអន្តរជាតិ អាកទួរ វែកគែន បន្តតាំងសំណួរដេញដោលចំពោះសាក្សី។

[១០:៣៨:៤៨]

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ការពិតទៅខ្ញុំចង់ឆ្លើយទៅនឹងការបដិសេធរបស់សហព្រះរាជអាជ្ញា <ដើម្បីនិយាយ>ផ្ទុយពី<អ្វីដែល>ខាងសហព្រះរាជអាជ្ញា<បានលើកឡើង។ វាបង្ហាញឱ្យឃើញ>ថាខ្ញុំ<មិន>បានព្យញរឿងដូច<គាត់ព្យនោះ>ទេ។ គាត់និយាយថា យើងមាន -- មុនពេលយើងមានបញ្ហាបច្ចេកទេសហ្នឹងនិយាយថា សាក្សីហ្នឹងបាននិយាយថា តាម៉ុក ហ្នឹងឱ្យមាសទៅ គាត់ដើម្បីឱ្យគាត់ដោះ

ដូរនាឡិកា។ តែខ្ញុំស្ដាប់ឮហ្នឹង ខ្ញុំអត់មានឮអ៊ីចឹងទេ។ <ខ្ញុំ>ឮថា តាម៉ុក ឲ្យជ្រូកដើម្បីទៅដូរថ្នាំ ឬក៏ផលិតផលដែលយកមកធ្វើថ្នាំទេ។ អ៊ីចឹងខ្ញុំសូមអនុញ្ញាតសួរសាក្សីដើម្បីសុំបំភ្លឺពីគាត់។

**សួរដោយលោក អាកឡូរ វ៉ែកកែន៖**

**ស៖** លោកសាក្សី មុនពេលសម្រាក តើលោកបាននិយាយថា តាម៉ុក នោះឲ្យមាសទៅលោកដើម្បីឲ្យលោកទៅដូរយកនាឡិកាដែរឬទេ?

**លោក រៀល សន៖**

**ឆ៖** បាទ អង្កាល់នុំងដល់ចាយលុយហើយ ដល់អស់លុយ លែងមានលុយ ក៏មន្ទីរពាណិជ្ជកម្មស្រុកថា "ចាំស្នើអង្គការឲ្យ ហើយចាំមកយក ហើយទៅៗ"។ហើយដល់ខ្ញុំទៅយកមាសហ្នឹងនៅកន្លែងមន្ទីរស្រុក នៅកន្លែងពាណិជ្ជកម្មស្រុកហ្នឹង គេឲ្យមកថា "អានេះមាសតា"។ មាសតា តាហ្នឹង តាម៉ុក។ យកទៅប្រើប្រាស់។ មានពីរលើក មួយលើកអាយកមាសហ្នឹងដោយខ្សែក អាដេញជ្រូកទៅដូរហ្នឹងដោយខ្សែក។ ដល់វាអស់មាស បានដេញជ្រូក។

[១០:៤០:៥០]

**ស៖** ហើយនាឡិកាទាំងអស់នេះ លោកបានយកទៅប្រគល់ឲ្យ តាម៉ុក ឬក៏យកទៅប្រគល់ឲ្យនៅមន្ទីរស្រុកទេ?

**ឆ៖** ធាតុពិតមិនមែនយកទៅដូរតែនាឡិកាទេ គឺដូចយកអីវ៉ាន់អីគ្រប់មុខ មកវិញហ្នឹង ឲ្យ -- យកឲ្យមន្ទីរស្រុកហ្នឹង ដឹងគេយកទៅឲ្យអ្នកណា គេយកឲ្យ តាម៉ុក ហើយព្រោះខ្ញុំឮគេថា មាសៗតាម៉ុក។ ហើយអ៊ីចឹងយកឲ្យតែត្រឹមមន្ទីរស្រុកហ្នឹង មន្ទីរស្រុកគេចែកទៅណាទៀត ខ្ញុំអត់ដឹងដែរ។ បានប៉ុន្មានៗអីគេយកទៅចែក។

**ស៖** ហើយក្រៅពីសម្ភារៈដែលយកមកផលិតថ្នាំ <នាឡិកា អីជាដើមហ្នឹង> តើលោកមានចាំថា មានបានដូរបានអីផ្សេងទៀតទេ ក្រៅពីរបស់របរទាំងអស់ហ្នឹង?

**ឆ៖** ក្រៅពីរបស់របរនាឡិកា ថ្នាំពេទ្យ មេថ្នាំពេទ្យហ្នឹង យកខ្សែអង្រឹង ហើយនិងកំណាត់ធ្វើអង្រឹងៗសម្រាប់កងទ័ព។

**ស៖** បាទ សូមអរគុណ។ ឥឡូវ ខ្ញុំសូមសួរថាតើលោក ក្នុងឋានៈលោកជាកម្មាភិបាលនៅក្នុងមន្ទីរពេទ្យហ្នឹង តើលោកមានរបបអាហារប្រចាំថ្ងៃដូចអ្នកដែលធ្វើការជាមួយលោកដែរឬទេ ហើយនិងអ្នកជំងឺដែរឬទេ? តើរបបអាហារហ្នឹងដូចគ្នាទាំងស្រុងតែម្ដង ឬក៏លោកនុំងមានបានរបបអាហារច្រើន

ជាងគេដែរ?

**ឆ៖** បាទ ធាតុពិតនៅក្នុងអង្គភាពខ្ញុំបាទនេះ គឺខ្ញុំបាទវាមិនមេទេ ប៉ុន្តែវាអនុមេដែរ។ ដូច្នេះលើការហូបចុក ហូបមូលគ្នា ហូបបបរៗដូចគ្នា អត់ៗដូចគ្នា ជួនកាលហូបជាមួយអ្នកជំងឺដែរ។ ពេទ្យខ្លះ ខ្ញុំក៏ធ្លាប់ហូបជាមួយអ្នកជំងឺ កាលណាវ៉េដួងហើយទៅហូបៗទាំងអស់គ្នា ហូបបបរ ស្មើភាពគ្នា មិនដែលគិតថា ដាំបាយហូបដោយឡែក តែម្តងក៏អត់ដែរ។

[១០:៤៣:៥៥]

**ស៖** ខ្ញុំចោទសំណួរនេះទៅលោក ព្រោះខ្ញុំកត់សម្គាល់ឃើញថា នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ D313/1.2.409, ERN ជាភាសាបារាំងគឺ 00808630, ជាភាសាអង់គ្លេសគឺ 00729049 ហើយជាភាសាខ្មែរគឺ 00418832-33។ បាទ នៅក្នុងកិច្ចសម្ភាសន៍ដែលបានធ្វើឡើង១៤ឆ្នាំកន្លងមកនេះ លោកបានរៀបរាប់ថា៖ “នៅពេលដែលខ្ញុំឮគេវ៉េដួងហៅទៅហូបបាយ ខ្ញុំ<ប្រញាប់>ទៅកន្លែងហូបបាយ<ភ្លាម> ខ្ញុំយក<បាយ>បីចាន ហើយនិងបាទសម្លព្រលឹតហ្នឹងហូបកន្លះចាន”។ <អានសម្រង់នេះហើយ ខ្ញុំឆ្ងល់ថា តើនោះជា>របបអាហារ<ដែលអ្នក>ទាំងអស់គ្នា<បានទទួលនៅមន្ទីរពេទ្យនោះឬ? មានន័យថា> ទាំងអ្នកជំងឺ ហើយនិងបុគ្គលិកហ្នឹង<ទទួលបានដូចគ្នា> គឺបាន<បួនចាន ឬ>បីចាន ហើយនិងសម្លព្រលឹតហ្នឹងហូបកន្លះចាន? រាល់ពេលហូបអាហារហ្នឹងគឺបានរបបដូចគ្នាអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ បានរបបហ្នឹងដូចគ្នា ប៉ុន្តែបបរមិនមែនបានបបរប៊ិកៗទេ បបរទឹកៗហ្នឹង អត់មានស្ងួរមានកាកទេ។ ពីរបី -- ថាពីរបីចានហ្នឹង ខ្ញុំពូកែហូបបបរ អ៊ីចឹងហូបបបរទឹកហ្នឹងអស់ពីរបីចានអ៊ីចឹង ហើយបានហូបសម្ល សម្លព្រលិតអីហ្នឹងកន្លះចានអ៊ីចឹងទៅ ហូបក្រោយទេ អត់មានហូបជាមួយគ្នាទេ។ ហើយដល់ចេញមកហូបទឹក ហូបអីនៅកន្លែងនេះមក។ ហើយហូបហ្នឹង ជួនកាលហូបពេទ្យហើយជាមួយគ្នា ជួនកាលហូបជាមួយអ្នកជំងឺ។ អ្នកជំងឺណាដែលមិនជាជំងឺធ្ងន់ យើងទៅហូបជាមួយគាត់។ ហើយអ្នកជំងឺណាធ្ងន់ អាហ្នឹងពេទ្យលើកបាយយកឱ្យហូបនៅគ្រែ នៅកន្លែងដេក។

[១០:៤៦:២៥]

**ស៖** បាទ អរគុណដែលបានឆ្លើយបំភ្លឺនេះ។ ខ្ញុំសូមចោទសំណួរមួយទៀត សំណួរខ្លីទេទាក់ទងទៅនឹងសមាជិកបុគ្គលិករបស់លោកម្នាក់ដែលឈ្មោះ អ៊ុច <ហាន> ដែលជាបុគ្គលិកពេទ្យដែលត្រូវបានបញ្ជូនទៅក្រាំងតាចាន់។ លោកបាននិយាយពីគាត់ហ្នឹង ហើយលោកបានថា គាត់ហ្នឹងឈ្មោះ អ៊ុច

ហាន បាទ អ៊ុច ហាន។ អ៊ីចឹង ខ្ញុំសូមសួរលោកថា តើគាត់មានឈ្មោះហៅក្រៅទេ? លោកស្គាល់ថា ឈ្មោះ អ៊ុច ហាន ហ្នឹងទេ ឬក៏គាត់មានឈ្មោះផ្សេងមួយទៀត?

**ផ៖** បាទ អង្គាល់គាត់នៅជាមួយខ្ញុំគាត់មានឈ្មោះតែមួយហ្នឹងទេ អត់មានឈ្មោះផ្សេង។

**ស៖** ចង់និយាយថា ឈ្មោះមួយណា?

**ផ៖** អង្គាល់នៅជាមួយខ្ញុំមិនៗមានឈ្មោះ អត់មានឈ្មោះជីតា ដាក់ឈ្មោះជីតា ហៅតែ ហានៗ ទេ អ៊ីចឹងអត់មាន អ៊ុច ហាន អីអត់ទេ។ ហៅថា "ហានៗ" ទទេ នារី ហានៗ។

**ស៖** តើលោកមានចាំដែរឬទេថា តើគាត់បានក្លាយជាចុងភៅនៅក្រាំងតាចាន់ហ្នឹង តាមរបៀបណាដែរ? <តើធ្វើម៉េចទើបលោកដឹងថា គាត់បានក្លាយជាអ្នកដាំបាយ?> តើដោយសារលោកធ្លាប់ហូបបាយនៅក្រាំងតាចាន់នោះឬយ៉ាងម៉េច?

**ផ៖** បាទ ធាតុពិតដែលខ្ញុំទៅបាញ់ថ្នាំមួយភ្លែតហ្នឹង ឃើញនារី ហាន ហ្នឹងអង្គុយដាំបាយ មិនមែនដាំបាយជាចុងភៅអីធំដុំទេ ដាំបាយឆ្នាំងតូច។ ឆ្នាំងប្រហែលជាអង្ករពីរកំប៉ុងអីហ្នឹង គាត់អង្គុយដាំបាយហ្នឹង។ ជួបគាត់មួយភ្លែតអត់សូវហ៊ាននិយាយរកទេ ខ្លាចៗណាស់ ដឹងថាវាជាអ្នកទោសទៅហើយ ហើយយើងទៅនិយាយរកអ្នកទោស គឺខ្លាចតែម្តង។

[១០:៤៩:00]

**ស៖** តើលោកធ្លាប់ហូបបាយនៅក្រាំងតាចាន់ទេ?

**ផ៖** បាទ មិនដែលទេ អត់ដែលសោះតែម្តង។

**ស៖** លោកបានឆ្លើយនៅក្នុងសវនាការនេះថា លោកបានទៅមន្ទីរនុ៎ង មន្ទីរក្រាំងតាចាន់ហ្នឹងតែម្តងទេ។ ក៏ប៉ុន្តែនៅពេលដែលលោកត្រូវបានគេសម្ភាសមុនពេលមកផ្តល់សក្ខីកម្មនៅសវនាការនេះ គឺថា យើងយល់ឃើញថា វាក្រៅពីពេលដែលលោកទៅបាញ់ថ្នាំហ្នឹងនៅក្រាំងតាចាន់ហ្នឹង គឺលោកក៏បានទៅចាក់ថ្នាំផងដែរ ដែលមានបុគ្គលិកពេទ្យទៅជាមួយលោកផងដែរ។ តើលោករក្សាចម្លើយដែលខ្ញុំរៀបរាប់អម្បាញ់មិញដែលលោកបានទៅមន្ទីរក្រាំងតាចាន់ហ្នឹង មុនហ្នឹងក៏ធ្លាប់ទៅចាក់ថ្នាំឱ្យគេដែរ ឬក៏បដិសេធចម្លើយហ្នឹង?

**ផ៖** បាទ ខ្ញុំបាទបដិសេធចម្លើយហ្នឹង ព្រោះខ្ញុំមិនដែល អត់ដែលទៅចាក់ថ្នាំនៅហ្នឹង មិនដែលសោះ។

**ស៖** លោកក៏បានពន្យល់ផងដែរថាលោកខំធ្វើយ៉ាងណាដើម្បីឱ្យគេហៅទៅមន្ទីរក្រាំងតាចាន់

នោះ ដោយសារលោកស្គាល់អ្នកយាមនៅក្រាំងតាចាន់។ តើលោក<ចាំថា>ធ្លាប់បាននិយាយអ៊ីចឹងទេ <>?

[១០:៥០:៥១]

**ផ៖** បាទ ខ្ញុំបាទអត់ដែលទេ អត់ដែលមានៗរឿងហ្នឹងសោះ គឺគ្មានដែលស្គាល់អ្នកយាមនៅកន្លែងហ្នឹងអី គឺមិនដែលស្គាល់ទេ អត់។ រឿងហ្នឹងគឺរឿងមិនពិត។

**ស៖** បាទ លោកសាក្សី ខ្ញុំសុំឲ្យលោកជួយបំភ្លឺលើជោគវាសនា ជាពិសេសគឺទាក់ទងនឹងអ្វីដែលលោកដឹងគឺថា ជោគវាសនារបស់ខ្មែរក្រោមមួយចំនួន។ ជាបឋម តើក្នុងឋានៈលោកជាកម្មាភិបាលនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ តើលោកធ្លាប់បាន<ឮ>ការណែនាំណាមួយទាក់ទងទៅនឹង<ការកំណត់គោលដៅជាក់លាក់លើ>ខ្មែរក្រោមដែរឬទេ? គឺការណែនាំដែលតម្រូវឲ្យប្រព្រឹត្តទៅលើខ្មែរក្រោមនេះ ខុសពីអ្នកដទៃ។

**ផ៖** បាទ គ្មានទេ គ្មានការណែនាំពីថ្នាក់លើថា ឲ្យអ្នកកម្ពុជាក្រោមហ្នឹងអ៊ីចេះអ៊ីចុះអីគឺអត់ អត់ដែលមានទេ។

**ស៖** ដោយមិនទទួលការណែនាំនោះ តើលោកធ្លាប់ជា -- លោកធ្លាប់ឃើញការប្រព្រឹត្តមិនល្អការធ្វើបាបទៅលើខ្មែរក្រហម នៅក្នុង -- លើខ្មែរក្រោម (សុំទោស) នៅក្នុងនៅកន្លែងដែលលោកធ្វើការនៅក្រោមរបបខ្មែរក្រហមដែរឬទេ?

**ផ៖** បាទ គឺគ្មាន។

[១០:៥៣:២២]

**ស៖** បាទ ឥឡូវខ្ញុំសុំបញ្ចប់សំណួរពីរបីទៀតមុននឹងចូលមកនិយាយអំពីសន្និសីទមួយដែលនិយាយអំពីការបោសសម្អាត ដែលលោកថា លោកបានចូលរួមកិច្ចប្រជុំ ឬក៏សន្និសីទហ្នឹង លោកនិយាយដូច្នេះកាលពីម្សិលមិញ បើខ្ញុំមិនច្រឡំទេ។ បាទ ម្សិលម៉្ងៃបាទ (សុំទោស) គឺកាលណោះ គឺម៉ោងដប់មួយជាង ម៉ោង ១១:១៦:០៩ វិនាទី លោកនិយាយថា បានលោកចូលរួមក្នុងកិច្ចប្រជុំនិយាយអំពីការបោសសម្អាត។ អ៊ីចឹង ខ្ញុំសុំសួរលោកថា តើលោកពិតជាបានចូលរួមក្នុងកិច្ចប្រជុំហ្នឹងដោយខ្លួនឯងផ្ទាល់ដែលនៅក្នុងកិច្ចប្រជុំនោះគេបាននិយាយអំពីការបោសសម្អាត?

**ផ៖** បាទ គឺខ្ញុំបាទចូលរួមផ្ទាល់ក្នុងការប្រជុំពីបញ្ហាបោសសម្អាត ជនជម្លៀសមកពីភ្នំពេញមកនិយាយរួមប្រជាជនថ្មី ហៅថាប្រជាជនថ្មី។

**ស៖** បាទ ត្រង់ចំណុចនេះហើយដែលខ្ញុំចាប់អារម្មណ៍ ពីព្រោះថា គេសួរឱ្យសុំឱ្យលោកប្រាប់ថាអ្នកណាអ្នកចូលរួមក្នុងកិច្ចប្រជុំហ្នឹងខ្លះ ហើយលោកឆ្លើយថា បាទ អ្នកដែលជម្លៀសចេញពីភ្នំពេញនោះក៏គេឱ្យចូលរួមប្រជុំនុំងដែរ។ អ៊ីចឹង ខ្ញុំ<ផ្តល់អំពីផ្នែកជាក់លាក់នេះ ដោយសារលោកហាក់ដូចជានិយាយ>ថា <នៅក្នុងកិច្ចប្រជុំនោះ លោកបានប្រាប់ប្រជាជនជាមុនថា ពួកគេ>នឹងត្រូវគេបោសសម្អាត។ អ៊ីចឹង សូមឱ្យលោកនិយាយលម្អិតអំពីចំណុចនេះបន្តិចបាទ។

[១០:៥៥:៣០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហមេធាវី -- សហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ប្រសិនបើមេធាវី<អះអាងថា សាក្សីនេះនិយាយដូច្នោះ -- > ខ្ញុំចាំថាសាក្សីមិនបាននិយាយអំពី<វត្តមានអ្នកជម្លៀស>នេះទេ។ ដូច្នេះ គួរតែមេធាវីការពារក្តី អាចលើកយកឯកសារយោងមកប្រាប់ដល់សាក្សី ដើម្បីឱ្យយើងដឹងថាតើគាត់និយាយអំពីអ្វី ឬក៏សាក្សីនិយាយអំពីអ្វី។

**ប្រធានអង្គជំនុំ៖**

បាទការលើកឡើងរបស់មេធាវី -- របស់សហមេធាវីរងអន្តរជាតិជាការត្រឹមត្រូវណាស់។ សូមលោកៗមេធាវីបាទ សំអាងលើឯកសារជាមូលដ្ឋានក្នុងការតាំងសំណួរ។

[១០:៥៦:២៩]

**លោក អាកទួរ វែកគែន៖**

បាទខ្ញុំនឹងធ្វើលោកប្រធាន។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** គឺៗប្រតិចារឹក -- ពង្រាងប្រតិចារឹកនៅថ្ងៃទី១៧ មីនា ឆ្នាំ២០១៥ គឺម៉ោង ១១:១៦:០៩ វិនាទី។ ចម្លើយរបស់លោកសាក្សី បាទខ្ញុំសូមអានសំណួរមុនសិន។ បាទសំណួរដែលចោទសួរពេលនោះ គឺថា “លោកសាក្សី ខ្ញុំចង់ដឹងថា តើមានការតែប្រជុំមួយទេ ដែលគេនិយាយ គេផ្តល់សេចក្តីណែនាំយ៉ាងដូច្នេះនេះ? ឬក៏មានកិច្ចប្រជុំជាច្រើនដែលគេបាននិយាយពីបញ្ហាទាំងអស់នេះ?”។ ខ្ញុំដកស្រង់ទៅមុននឹងបន្តិចទៀត ដើម្បីឱ្យកាន់តែច្បាស់ជាងហ្នឹង សាក្សីគាត់ឆ្លើយតបទៅនឹងការដកស្រង់មួយ កាល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នោះ ការដកស្រង់ទាក់ទងទៅនឹងខ្មែរក្រោមដែលត្រូវបានចោទប្រកាន់នៅក្នុងកិច្ចប្រជុំមួយថា ខ្មែរក្រោមនេះជាភ្នាក់ងារ កា.ហ្សេ.បេ ហើយនិងជាគិញវៀតណាម។ ហើយខ្ញុំសូមចូលមកនិយាយពីចម្លើយរបស់គាត់វិញម្តង គឺថាក្រោយម៉ោង១១:១៦:០៩សីហ្គុងបន្តិច "ទាក់ទងនឹងការបោសសម្អាតនេះ អ្វីដែលខ្ញុំ<ដឹង>គឺ<ថា>ការ<>បញ្ហា<បែប>នេះ បាន<>ចេញ<>នៅក្នុងកិច្ចប្រជុំដែលខ្ញុំបានចូលរួម។ សំណួរ៖ តើលោកអាចប្រាប់បានទេ ថាតើកិច្ចប្រជុំនោះប្រព្រឹត្តទៅនៅកន្លែងណា? ចម្លើយ៖ គឺនៅកន្លែងៗចង្ក្រានបាយសហករណ៍អង្គរកា នៅក្នុងកន្លែងរោងបាយ។ សំណួរ៖ តើកម្មាភិបាលស្រុកនោះ មានវត្តមាន<> មានចំនួនប៉ុន្មាននាក់ៗ? ហើយមានមេឃុំផងដែរ<ទេ? បើមាន> តើ<មេឃុំប៉ុន្មាននាក់មានវត្តមាន>? ចម្លើយ៖ ខ្ញុំមិនចាំពីចំនួនអ្នកចូលរួមទាំងអស់ទេ តែខ្ញុំដឹងថា មានអ្នកតំណាងឃុំជិតៗនុ៎ង ហើយក៏មានអ្នកដែលជម្លៀសមកពីភ្នំពេញ និង តាកែវផងដែរ ជាច្រើន"។

[១០:៥៨:៤០]

ដូច្នេះ ខ្ញុំសូមផ្លោះទៅ<ពីរ>ទំព័រក្រោយ ហួសហ្នឹងបន្តិច សាក្សីបញ្ជាក់គឺថានៅម៉ោង១១:១៨:៥១វិនាទី ទាក់ទងប្រធានបទកិច្ចប្រជុំនេះដដែល។ <នេះជាអ្វីដែលសាក្សី>និយាយ< ខ្ញុំសូមដកស្រង់៖ "គេបានបញ្ជាក់>អំពីការបោសសម្អាតនៅក្នុងកិច្ចប្រជុំហ្នឹង <អ្នកដែល>ត្រូវ<>បោសសម្អាត<គឺជាសមាជិកកងទ័ព>ដែលចាប់ពី<ពាក់អាក់ស៊ីឡង់>ឡើងទៅ។ ហើយបើចំពោះពួករដ្ឋបាលវិញហ្នឹង គឺថាចាប់ពីជំទប់<ទី១>ទៅត្រូវបោសសម្អាត<>។ បាទនេះគឺនៅមុនម៉ោង<១១:២១:០១>វិនាទី។ បាទនេះជាចម្លើយរបស់លោក លោកសាក្សី កាលពីថ្ងៃ១៧ មីនា ឆ្នាំ២០១៥។

អ៊ីចឹង ខ្ញុំឆ្ងល់ដែរថា ហេតុអ្វីក៏គេនិយាយអំពីការបោសសម្អាតចំពោះមុខអ្នកដែលនឹងក្លាយជាអ្នកដែលត្រូវគេបោសសម្អាតនោះ។ អ៊ីចឹង ខ្ញុំសូមសួរឲ្យលោកបញ្ជាក់ថា សូមឲ្យនិយាយឲ្យបានលម្អិតបន្តិចមើលពីកិច្ចប្រជុំនេះ។ តើគេនិយាយអ្វីខ្លះបាទ?

**លោក វៀល សន៖**

**ឆ៖** បាទខ្ញុំបាទមិនបានរៀបរាប់អំពីថា ប្រជាជនដែលត្រូវគេបោសសម្អាតមករួមប្រជុំក្នុងនោះដែរទេ គឺគ្មានទេ មានតែគណៈឃុំ មេភូមិ ហើយនិងតំណាងមន្ទីរជុំវិញស្រុកម្នាក់ៗហ្នឹង ដូចជាខ្ញុំអីជាដើមហ្នឹង ខ្ញុំហ្នឹងតំណាងឲ្យមន្ទីរពេទ្យ អ៊ីចឹងទៅ។ បើថាអ្នកដែលសមាជិកអង្គប្រជុំគឺគ្មានៗទេ អត់មានទេ មានតែកម្មាភិបាល។

**ស៖** តើមានមូលហេតុអីមួយច្បាស់លាស់ដែរឬទេ ដែលលោកក្នុងឋានៈជាប្រធានមន្ទីរពេទ្យ

នេះដែលត្រូវចូលរួមប្រជុំហ្នឹង ក្នុងកិច្ចប្រជុំហ្នឹង ដែលគេនិយាយអំពីការបោសសម្អាតហ្នឹង? មានមូលហេតុអ្វីជាក់លាក់ទេ?

**ឆ៖** ខ្ញុំថាដូចជាគ្មានមូលហេតុអីច្បាស់លាស់ក្រៅពីហៅមេភូមិ មេឃុំហ្នឹងទៅ ប្រាប់ពីរឿងបោសសម្អាត។ កាលនុំងគេប្រាប់ថាបោសសម្អាតខ្មាំងអ៊ីចឹងហ្នង ដូចមានតែប៉ុណ្ណឹងទេ។

[១១:០១:២៥]

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែលោកមិនមែនជាប្រធានភូមិ ហើយមិនមែនមេឃុំអីទេ អ៊ីចឹងហេតុអ្វីក៏លោកមានវត្តមាននៅក្នុងកិច្ចប្រជុំនេះដែរ?

**ឆ៖** បាទ គឺបើគណៈស្រុកប្រជុំ អ៊ីចឹងគឺហៅមន្ទីរជុំវិញមន្ទីរស្រុកហ្នឹង ហៅមកប្រជុំទាំងអស់គ្នាឲ្យដឹង។ និយាយរួមដូចហៅមកព្រមានអ៊ីចឹង ហៅពេទ្យមកប្រជុំអ៊ីចឹងវិញ ហៅដូចហៅមកព្រមានឲ្យបានប្រយ័ត្នប្រយែងអ៊ីចឹងទៅ នៅមន្ទីរពេទ្យ។

**ស៖** តើការប្រុងប្រយ័ត្នហ្នឹង នៅមន្ទីរពេទ្យហ្នឹង យើងត្រូវយល់យ៉ាងម៉េចដែរ? យើងអាចបកស្រាយយ៉ាងម៉េចដែរ ការប្រុងប្រយ័ត្ននៅមន្ទីរពេទ្យហ្នឹង ទាក់ទងនឹងខ្មាំងហ្នឹង?

**ឆ៖** បាទ ធាតុពិតកាលពីជំនាន់ហ្នឹង គឺនៅមន្ទីរពេទ្យយប់ឡើងយាមកាមច្បាស់លាស់ណាស់ ព្រោះមានចោរលួចអង្ករ ជាពិសេសលួចតែអង្ករ ច្រើនណាស់ ម្សប់ៗ អ៊ីចឹងទៅ យើងដេញទៅ ដូចដេញសត្វអីអ៊ីចឹងលួចអង្ករ ជាពិសេសលួចអង្ករតែម្តង។ មានអង្ករបន្តិចបន្តួចអីលួច ជួនកាលលួចខ្ទះដាំបាយរត់ទៅខ្ចីសហករណ៍ជិតហ្នឹង មកបបរឲ្យអ្នកជំងឺហូបទៅ។

[១១:០៣:២១]

**ស៖** តើចំណុចទាំងអស់នេះ ពាក់ព័ន្ធនឹងការបោសសម្អាតត្រង់ណាដែរ?

**ឆ៖** ខ្ញុំៗនិយាយនេះន៎ និយាយតែមន្ទីរពេទ្យទេ មន្ទីរពេទ្យបោសសម្អាតអ្នកដែលមកលួចហ្នឹងអាចោរលួចអង្ករហ្នឹង កុំឲ្យវាមាន ព្រោះនៅតាមសហករណ៍អត់មានចោរលួចអីបានទេ តែចោរ តែលួចចាប់ហើយ ដឹង។ តែនៅមន្ទីរពេទ្យសុទ្ធតែស្រីៗគ្មានដឹង ចាប់មិនបាន វារត់អីអ៊ីចឹងទៅ។ លួចជួនកាលអត់ដឹងផង លួចអស់អង្ករទៅ។ តែប៉ុណ្ណឹង មិនមានការ -- មិនមាន អើចុះយើងជាពេទ្យមិនមែនទៅ -- គេមិនណែនាំឲ្យទៅបោសសម្អាតអីគឺអត់ទេ គេមិនដែលទេ។ បើនិយាយក្នុងអង្គប្រជុំជាមួយគ្នាហ្នឹង គឺនិយាយចំពោះតែមេភូមិ មេឃុំទៅ តែចំពោះពេទ្យហ្នឹង អត់ទេ។

**លោក អាកឡូវ វែកគែន៖**

បាទ លោកប្រធានខ្ញុំអស់សំណួរហើយលោកប្រធាន។ បាទ លោកសាក្សីសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមអរគុណចំពោះលោក វៀល សន ដែលបានចំណាយពេលវេលាមានតម្លៃមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សី ក្នុងរយៈពេល២ថ្ងៃកន្លះកន្លងមកនេះ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។

ការផ្តលសក្ខីកម្មរបស់លោកមកដល់ពេលនេះបានដល់ទីបញ្ចប់ហើយ លោកមានវត្តមាននៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏ទីគោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

អង្គជំនុំជម្រះក៏សូមអរគុណចំពោះលោកមេធាវីប្រឹក្សា ឌុច ផារី ដែលបានចូលរួមប្រឹក្សាសាក្សីនៅក្នុងពេលស្តាប់សក្ខីកម្មសាក្សីរូបនេះ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅវិញបានហើយ។

សូមអញ្ជើញចាកចេញទៅចុះ!

*(សាក្សីចេញពីបន្ទប់សវនាការ)*

[១១:០៦:២៤]

អង្គជំនុំជម្រះបានទទួលសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ឯកសារ E344 និង E344.1។ សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូង៖ ១) ឲ្យកោះហៅ និងស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី D22/2500 ដោយអនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង។ ២) ទទួលយកភស្តុតាងនូវព័ត៌មានបន្ថែមដែលមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ“ក” អនុលោមតាមវិធាន៨៧(៣) និង៨៧(៤) នៃវិធានផ្ទៃក្នុង។

បាទឥឡូវនេះអង្គជំនុំជម្រះជូនវេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមប្បវេណីមុនគេប្រសិន បើមានអ្វីបន្ថែមលើសំអាងហេតុ លើសំណើសុំដែលខ្លួនលើកឡើង គឺអាចបន្ថែមបាន មានពេល៥នាទី។

[១១:០៧:៣៨]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ <ខ្ញុំមិនរំពឹងថានឹងបង្ហាញសារណានេះទេ ព្រោះ>ខ្ញុំគិតថាសំណើរបស់យើងគ្រប់គ្រាន់ហើយ សំណើជាលាយលក្ខណ៍អក្សរនោះ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គឺខ្ញុំចង់បានការអនុញ្ញាតឲ្យខ្ញុំឆ្លើយតបទៅនឹងការជំទាស់របស់សហព្រះរាជអាជ្ញា ឬមេធាវីការពារក្តី។ ដូច្នេះខ្ញុំគិតថា គឺសំណើជាលាយលក្ខណ៍អក្សររបស់យើង គឺមានភាពពាក់ព័ន្ធគ្រប់គ្រាន់អស់ហើយ វាឆ្លើយតបទៅនឹងលក្ខខណ្ឌនៃវិធាន៨៧(៣) ហើយវាក៏ឆ្លើយតបទៅនឹងលក្ខខណ្ឌនៃវិធាន៨៧(៤) វាមានសំអាងហេតុគ្រប់គ្រាន់ហើយ។ ហើយវាមានប្រយោជន៍សម្រាប់ការលាតត្រដាងការពិត។ យើងបានពន្យល់លម្អិតអំពីមូលហេតុដែលថាយើងមិនទទួលបានព័ត៌មានទាំងអស់នេះមុននឹងធ្វើសំណើ។ ហើយយើងក៏បានពន្យល់ផងដែរអំពីមូលហេតុ ដែលយើងស្នើសុំឲ្យមានការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីនេះ ដោយសារតែគាត់មានព័ត៌មានពាក់ព័ន្ធទៅនឹងអំពើរបស់ជនជាប់ចោទ។ ដូច្នេះខ្ញុំអត់មានបន្ថែមទៀតទេ ក៏ប៉ុន្តែខ្ញុំនឹងឆ្លើយតប ហើយនិងផ្តល់ព័ត៌មានបន្ថែមប្រសិនបើមេធាវីការពារក្តី ឬអង្គជំនុំជម្រះ ឬសហព្រះរាជអាជ្ញាសុំការបំភ្លឺបន្ថែមនៅលើចំណុចណាមួយពីខាងយើងខ្ញុំនោះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅទៀត អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំសូមគាំទ្រទៅលើសំណើនេះ។ ភាពពាក់ព័ន្ធនៃព័ត៌មានគឺបង្ហាញច្បាស់ហើយ។ អ្វីដែលខ្ញុំចង់បន្ថែម ហើយខ្ញុំចង់ឲ្យអង្គជំនុំជម្រះចាប់អារម្មណ៍ គឺថានៅក្នុងតុលាការនេះ ភស្តុតាងនៃការប្រព្រឹត្ត និងអំពើរបស់ជនជាប់ចោទអាចទទួលយកបាន លុះត្រាតែសាក្សី <ឬក្នុងករណីនេះ ដើមបណ្តឹងរដ្ឋប្បវេណី>មកបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះ។ នេះ<ជាការសម្រេចពីមុនមក> ហើយ<ខ្ញុំគិតថា នេះ>គឺជាមូលហេតុ<បន្ថែមមួយទៀត>ដែលថា គួរតែផ្តល់ការអនុញ្ញាតទៅតាមសំណើនេះ។ សូមអរគុណលោកប្រធាន។

[១១:១០:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅមេធាវីការពារក្តី ដំបូងនេះក្រុមមេធាវីការពារក្តីលោក នួន ជា តើមានមតិយោបល់អ្វីទេលើសំណើសុំនេះ?

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោក។ តាមពិតទៅយើងដូចជាមិនឃើញភាពពាក់ព័ន្ធរបស់សក្ខីកម្មមួយនេះឡើយ។ ប្រសិនបើទោះបីជា នួន ជា បានទៅមើលកន្លែងការដ្ឋាន<លាយបូរ>នោះក៏ដោយ ក៏វាហាក់បីដូចជាមិនបានជួយអ្វីទៅដល់ហេតុការណ៍ ឬក៏ព្រឹត្តិការណ៍នោះឡើយ។ បាទ បើទោះបីជាគាត់ទៅពិនិត្យមើលការដ្ឋាននោះ ថាតើវាបានបន្ថែមអ្វី ឬក៏ជួយអ្វីដល់ភស្តុតាងទាក់ទងទៅនឹងការចោទប្រកាន់ពីការទទួលខុសត្រូវដែលគាត់បានទៅទីនោះ។ ដូច្នេះប្រហែលជាខ្ញុំ<មើល>ឃើញ<បញ្ហានេះមិនច្បាស់ទេ ប៉ុន្តែ>ខ្ញុំមិនឃើញពីភាពពាក់ព័ន្ធដែលបង្ហាញពី<ទស្សនកិច្ច>របស់ នួន ជា និង ប៉ុល ពត <ទៅ>ការដ្ឋាននោះ<ទេ>។ ដូច្នេះ ចំពោះខ្ញុំគឺថាទោះបីកោះហៅ ឬក៏មិនកោះហៅ គឺវាមិនមានអ្វីជាបញ្ហាសំខាន់ឡើយចំពោះខ្ញុំ គឺខ្ញុំមិនខ្វល់អំពីបញ្ហានេះ។

[១១:១១:៣៧]

**លោក អាកទួរ វែកគែន៖**

បាទលោកប្រធាន យើងគោលជំហរយើងក៏ដូចគ្នាដែរ។ យើងគិតថាសំណើនេះវាដាក់យឺតពេលទៅហើយ ដែលដាក់ដោយដើមបណ្តឹងរដ្ឋប្បវេណី។ នេះជាការបង្ខិនពេលវេលា ជាពិសេសនៅពេលដែលគាត់បំពេញទម្រង់ព័ត៌មាននោះ បុគ្គលរូបនោះបានបញ្ជាក់ថា គាត់មានបញ្ហាស្មារតី គឺឯកសារ D22/2500 ហើយគាត់ក៏បាត់បង់ការចងចាំដែរ។ ហើយបន្ទាប់មកគេមានបញ្ជាក់ -- គេមានផ្តល់លិខិតបញ្ជាក់ដែលមានរៀបរាប់ព័ត៌មានលម្អិតមួយចំនួន។ <ដូច្នេះ ចុងក្រោយបង្អស់ ដំណោះស្រាយនោះគឺប្រហែលជាត្រូវកោះហៅគាត់មក> ក៏ប៉ុន្តែចំពោះខ្លួនខ្ញុំ ខ្ញុំថាបើហៅមកដូចជាធ្វើឲ្យខាតពេលវេលាទៅវិញទេ ក៏ប៉ុន្តែអង្គជំនុំជម្រះជាអ្នកសម្រេច។ ហើយខ្ញុំគិតថា<មិនត្រឹមតែ>បញ្ហាខួរក្បាល ឬក៏បញ្ហាស្មារតី<ដែលរាយការណ៍ដោយបុគ្គលនេះ ដែល>មានភាពខ្មាស់គ្នាទៅនឹងអ្វីដែលគាត់ចងចាំ <ប៉ុន្តែដោយសារតែការយឺតយ៉ាវនៃសំណើនេះផងដែរ> ខ្ញុំគិតថាគួរតែបដិសេធចោលនូវសំណើនេះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខដើម្បីឆ្លើយតបចុងក្រោយ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឆ្លើយតបមួយចំណុចម្តងៗ ដោយខ្លី។ ខ្ញុំយល់អំពីការលើកឡើងរបស់លោក កូប៉េ គាត់គិតថា វត្តមានរបស់ នួន ជា នៅលាយបូរនោះមិនមែនជាធាតុផ្សំពាក់ព័ន្ធទៅនឹង ដែលយើងហៅថា អំពើនិងអាកប្បកិរិយាទេ។ <តាមការយល់ឃើញរបស់ខ្ញុំ គឺមិនមានកំហុសនោះទេ ចំពោះអង្គហេតុដែលថាតាមទស្សនះ>យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះនោះ វត្តមានរបស់ជនជាប់ចោទនៅការដ្ឋានណាមួយនោះ វាគឺជាអំពើ ហើយនិងសកម្មភាពរបស់ជនជាប់ចោទ។ ដូច្នេះយោងតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះ អង្គជំនុំជម្រះគួរតែកោះហៅបុគ្គលនេះ ដើម្បីឲ្យគាត់មកពន្យល់បង្ហាញអំពីអ្វីដែលគាត់បានឃើញ ហើយមេធាវីការពារក្តីក៏អាចសួរសំណួរទៅកាន់គាត់ដែរ។ ដូច្នេះ <សម្រាប់ខ្ញុំវាហាក់ដូចជាថា តាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះ> វត្តមានរបស់ នួន ជា និង ខៀវ សំផន នៅក្នុងឃុំលាយបូរនោះ គឺវាស្ថិតនៅក្នុងអ្វីដែលយើងហៅ អំពើនិងអាកប្បកិរិយារបស់ជនជាប់ចោទនោះ។

[១១:១៤:២៨]

គាត់ថាសំណើយើងយឺតពេលនោះ ខ្ញុំសូមឆ្លើយតបទៅនឹងមេធាវីការពារក្តីលោក ខៀវ សំផន ថាយើងបានពន្យល់ច្បាស់នៅក្នុងសំណើជាលាយលក្ខណ៍អក្សរហើយ ថាហេតុអ្វីបានជាយើងមិនមានព័ត៌មាននេះពីមុនមកនោះ។ ហេតុអ្វីបានជាទើបតែថ្ងៃនេះ យើងស្នើសុំផ្តល់ព័ត៌មានបែបនេះជូនទៅភាគីនិងអង្គជំនុំជម្រះនោះ។ អង្គជំនុំជម្រះគួរតែចាត់ទុកថា សំណើរបស់យើងមិនយឺតពេលទេ ពីព្រោះថាយើងបានពន្យល់លម្អិតហើយ ថាមូលហេតុអីបានជាយើងមិនទទួលបានព័ត៌មាននេះ មុនពេលដែលយើង បានដាក់សំណើទៅអង្គជំនុំជម្រះនោះ។ ហើយគាត់ថា ជាការបង្ខិនពេលវេលា។ ចំពោះយើង យើងគិតថា ការស្តាប់សក្ខីកម្មគាត់ហ្នឹង គឺវាមានសារៈសំខាន់ក្នុងការបង្ហាញការពិតទៅវិញទេ ពីព្រោះថាគាត់នឹងបង្ហាញថា ជនជាប់ចោទមានវត្តមាននៅក្នុងឃុំលាយបូរ ដែលជា<ឃុំ>មួយស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះយើងនេះ។ ដូច្នេះ អ្វីៗសម្រេចទៅលើការវិនិច្ឆ័យរបស់អង្គជំនុំជម្រះ។ ក៏ប៉ុន្តែបើយើងមើលវិធាន៨៧(៣) និង៨៧(៤) <ក៏ដូចជា>យោងតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះនោះ <ខ្ញុំជឿថា> អង្គជំនុំជម្រះ<នឹងទទួលយក>សំណើ<នេះ> ហើយ<នឹង>កោះហៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដើម្បីមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះ -- សូមអញ្ជើញលោក អាកទួរ វែកគែន!

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំកត់សម្គាល់ឃើញថា គេអត់ឆ្លើយតបមកយើងពាក់ព័ន្ធទៅនឹងបញ្ហាសុខភាពផ្នែកស្មារតីរបស់ដើមបណ្តឹងនោះទេ។ <ខ្ញុំសូមរំឭកថា នៅក្នុងសំណើនេះ> គាត់និយាយថានឹង<ផ្តល់សក្ខីកម្ម ផ្តល់សក្ខីកម្ម ផ្តល់សក្ខីកម្ម។ ពួកគេនិយាយអំពីការ>បង្ហាញការពិត ក៏ប៉ុន្តែ<សាក្សីរូបនេះនៅតែជាដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ ហើយ>យើង<ត្រូវរក្សាទុកការពិតនេះនៅក្នុងចិត្តជានិច្ច>។

[១១:១៦:៣៥]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំសូមឆ្លើយតបលោកប្រធាន។ ពាក់ព័ន្ធទៅនឹងបញ្ហាសុខភាព<ផ្លូវចិត្ត> ខ្ញុំបញ្ជាក់ថា ខ្ញុំបានជួបគាត់ហើយហើយខ្ញុំឃើញថា គាត់ដូចជាមិនមានបញ្ហាអីទេ គាត់អាចមកផ្តល់សក្ខីកម្មបាន។ ចំពោះពាក្យដែលខ្ញុំ ប្រើពាក្យថា “សក្ខីកម្មៗ” ជាច្រើនដងនេះគឺថាវា<ជាពាក្យពិតដែលខ្ញុំចង់និយាយ។ ប៉ុន្តែជាការពិតហើយ ខ្ញុំត្រៀមខ្លួននឹងព្រមរួចជាមួយនឹងមេធាវីការពារក្តី>ថា ដើមបណ្តឹងរដ្ឋប្បវេណីនេះ<មិនផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះទេ ប៉ុន្តែថា ពួកគេត្រូវបានស្តាប់ ហើយនិងបានទទួលស្គាល់។> អត់មានបញ្ហាអីទេ<ពាក់ព័ន្ធនឹងរឿងនេះ>។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអរគុណចំពោះរាល់មតិយោបល់របស់គូភាគីដែលបានលើកឡើងពាក់ព័ន្ធនឹងបញ្ហាសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើបញ្ហានេះ។ អង្គជំនុំជម្រះនឹងយកមតិយោបល់របស់ភាគីដែលបានលើកឡើងលើសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅពិនិត្យពិចារណា ហើយនិងចេញសេចក្តីសម្រេចទៅលើបញ្ហានេះឲ្យបានឆាប់តាមដែលអាចធ្វើទៅបាននាពេលខាងមុខ។

ហើយជាចុងក្រោយនេះ សវនាការនៅព្រឹកនេះ អង្គជំនុំជម្រះសូមចេញសេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំផ្អាកសវនាការ ដោយសារតែការដាក់បង្ហាញឯកសារថ្មីៗ ពីក្នុងសំណុំរឿង០០៣ និង ០០៤។

[១១:១៧:៥៥]

នៅពេលនេះ អង្គជំនុំជម្រះឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តីដែលបានស្នើសុំផ្អាកសវនាការ ដើម្បីអាចឲ្យពួកគាត់មានពេលវេលាអាន និងវិភាគទៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីពីក្នុងសំណុំរឿង០០៣ និង០០៤។

អង្គជំនុំជម្រះបានពិចារណាទៅលើសំណើសុំលាយលក្ខណ៍អក្សររបស់ នួន ជា ចម្លើយតបផ្ទាល់មាត់របស់សហព្រះរាជអាជ្ញា និងសេចក្តីសន្និដ្ឋានរបស់ភាគីផ្សេងទៀតក្នុងអំឡុងពេលសវនាការ ជាពិសេសសវនាការថ្ងៃទី០៤ និងទី០៥ ខែមីនា ឆ្នាំ២០១៥។ ការដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីពីក្នុងសំណុំរឿង០០៣ និង០០៤ មានជាបន្តបន្ទាប់ ចាប់តាំងពីខែតុលាឆ្នាំមុន។ ហើយអង្គជំនុំជម្រះបានផ្តល់ពេលវេលាបន្ថែមដល់ភាគីដើម្បីឲ្យពិនិត្យមើលឡើងវិញលើឯកសារទាំងនេះក្នុងករណីចាំបាច់។

នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ មេធាវីការពារក្តី នួន ជា បានចង្អុលបង្ហាញថា មេធាវីការពារក្តីបានអានឯកសារ ដែលខ្លួនបានទទួលរហូតមកដល់ពេលនោះ ចាប់តាំងពីពេលនោះមក ការិយាល័យសហព្រះរាជអាជ្ញា បានដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយចំនួន២២៦បន្ថែមទៀត ដែលមានប្រហែល ២៥០០ទំព័រ ជាភាសាអង់គ្លេស និង ២៣០០ទំព័រជាភាសាខ្មែរ។ អង្គជំនុំជម្រះបានពិចារណាទៅលើទំហំនៃឯកសារដែលបានដាក់បង្ហាញនាពេលថ្មីៗនេះ និងកាលវិភាគសវនាការនាពេលបច្ចុប្បន្ននេះ។

[១១:១៩:៤៨]

លើសពីនេះទៀត អង្គជំនុំជម្រះកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយល់ព្រមធ្វើការកែប្រែការដាក់កំហិតពាក់ព័ន្ធនឹងការប្រើប្រាស់ឯកសារ ដែលត្រូវបានដាក់បង្ហាញ ដែលការប្រែនេះនឹងអនុញ្ញាតឲ្យសមាជិកនៅក្នុងក្រុមជាច្រើននាក់មានលទ្ធភាពពិនិត្យមើលលើឯកសារទាំងនោះ និងធ្វើការស្វែងរកពាក្យពេចន៍បាន។

អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា អង្គជំនុំជម្រះមានបំណងកែប្រែលំដាប់លំដោយអង្គហេតុ នៃការដ្ឋានការងារ ដោយពន្យារពេលធ្វើសវនាការទៅលើអង្គហេតុទំនប់ត្រពាំងថ្ម ដែលមានការជាប់ពាក់ព័ន្ធទៅនឹងកំណត់ហេតុស្តាប់ចម្លើយថ្មីៗមួយចំនួន រហូតដល់ការស្តាប់សក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុព្រលានយន្តហោះកំពង់ឆ្នាំងត្រូវបានបញ្ចប់។

ដោយផ្អែកទៅលើការពិចារណាទាំងនេះ អង្គជំនុំជម្រះសម្រេចផ្អាកសវនាការដែលគ្រោងធ្វើនៅថ្ងៃទី០៦ ខែមេសា រហូតដល់ថ្ងៃទី០៩ ខែមេសា ហើយនិងចាប់ផ្តើមធ្វើសវនាការឡើងវិញ បន្ទាប់ពីការ

ឈប់សម្រាកចូលឆ្នាំខ្មែរ គឺនៅថ្ងៃទី២១ ខែមេសា ដើម្បីស្ដាប់សក្ខីកម្មរបស់សាក្សីបន្ទាប់ទៀត។ អង្គជំនុំជម្រះយល់ឃើញថា ការផ្អាកសវនាការនេះ នឹងផ្ដល់ឱកាសឲ្យមេធាវីការពារក្ដី និង ដើមបណ្ដឹងរដ្ឋ -- និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យមើលឯកសារ ដែលបានដាក់បង្ហាញទាំងនេះ។

[១១:២១:៣១]

បាទ នេះជាការឆ្លើយតប ដែលអង្គជំនុំជម្រះបានជម្រាបភាគីថ្ងៃមុនថា យើងនឹងចេញសេចក្ដីសម្រេចផ្ទាល់មាត់នៅថ្ងៃនេះ។ ហើយអង្គជំនុំជម្រះសូមជម្រាបថា ដោយមានបញ្ហាផ្លាស់ប្ដូរនូវកាលបរិច្ឆេទនៃការសវនាការ មូលហេតុបញ្ហាសាក្សីបម្រុងដែលយើងបានកោះអញ្ជើញមកថ្ងៃនេះ គាត់បានមានបញ្ហាសុខភាពធ្ងន់ធ្ងរមិនអាចធ្វើសវនាការបាន។ ដូច្នេះ នៅក្នុងសប្ដាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងកោះហៅ ពិនិត្យលទ្ធភាពដើម្បីកោះហៅបុគ្គលដទៃផ្សេងទៀត មកផ្ដល់សក្ខីកម្មនៅថ្ងៃចន្ទសប្ដាហ៍ក្រោយនេះ។ ហើយចំពោះការផ្លាស់ប្ដូរក្នុងការស្ដាប់សក្ខីកម្មបុគ្គលណា រូបណានោះ អង្គជំនុំជម្រះនឹងជូនដំណឹងទៅដល់ភាគីតាមរយៈអ៊ីម៉ែលរបស់មន្ត្រីជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងនៅរសៀលនេះ ឬនៅថ្ងៃស្អែក បន្ទាប់ពីអង្គជំនុំជម្រះពិនិត្យពិចារណាលើបញ្ហានេះ សម្រេចចុងក្រោយ នៅរួចនឹងជូនដំណឹងតាមរយៈមន្ត្រីច្បាប់ជាន់ខ្ពស់។ សូមភាគីជ្រាប។

បាទ ហើយសវនាការនៅថ្ងៃនេះ ឃើញថាវាអត់មានការងារអីទៀតទេ ដោយសារមូលហេតុបញ្ហាសុខភាព -- សាក្សីបម្រុងមានសុខភាព --
មានបញ្ហា? សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១១:២៣:០៥]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់លើកយកបញ្ហាមួយ ចង់ឲ្យអង្គជំនុំជម្រះចាប់អារម្មណ៍ <ដែលអាចប៉ះពាល់ដល់ការសម្រេចរបស់អង្គជំនុំជម្រះ> ទាក់ទងទៅនឹង<ការ>កំណត់កាលបរិច្ឆេទ<និងសាក្សី>នៅសប្ដាហ៍ក្រោយ។ ចំណុចអស់នេះ គឺទាក់ទងទៅនឹង 2-TCW-809 កំណត់ហេតុស្ដាប់ចម្លើយថ្មីដែលយើងបានបង្ហាញ <ក្នុងក្រុមធំ> ដែលយើងបានបញ្ជាក់កន្លងមកនោះ គឺមិនមានព័ត៌មានអ្វីពាក់ព័ន្ធទៅនឹងស្រុកត្រាំកក់នោះឡើយ។ ដូច្នេះហើយសក្ខីកម្មរបស់គាត់គឺអាចថាមានប្រសិទ្ធភាព។ ដូច្នេះនៅពេលដែលយើងចាប់ផ្ដើមរៀបចំ គាត់ក៏ជាមនុស្សម្នាក់ដែលត្រូវបានគេបញ្ជូនទៅភូមិភាគ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កណ្តាលនៅក្នុងឆ្នាំ៧៧ ហើយគាត់ដឹង<ព័ត៌មានសំខាន់មួយចំនួន>ពាក់ព័ន្ធអំពីការបោសសម្អាតនៅក្នុងភូមិភាគ<កណ្តាល>ផងដែរ។ ដូច្នេះ កំណត់ហេតុស្តាប់ចម្លើយ<២២០ ដែលយើងបានបង្ហាញ>ហ្នឹង<ខ្ញុំជឿថា មានបទសម្ភាសន៍ប្រហែល២០ ទៅ២៥> ដែលពាក់ព័ន្ធទៅនឹងការបោសសម្អាតនៅភូមិកណ្តាល។ ដូច្នេះ ក្នុងចំណោមក្រុមទាំង<>នោះ មានប្រហែលជាប្រាំទៅ១០របស់កម្មាភិបាលដែលមិនមែនមកពីស្រុកត្រាំកក់នោះ<ទេ ប៉ុន្តែមកពីតំបន់ផ្សេងទៀតនៃ>ភូមិភាគនិរតី<>ដែលត្រូវបានគេបញ្ជូនទៅកំពង់ចាម ក្នុងពេលជាមួយគ្នានេះ។ <ទាំងអស់នេះមិនមែន>ជាកំណត់ហេតុស្តាប់ចម្លើយដែល<ខ្ញុំរំពឹងថា>នឹងប្រើប្រាស់<នោះទេ។ ប៉ុន្តែ>ខ្ញុំចង់<ធ្វើឲ្យប្រាកដ>ថា តុលាការក៏ដូចមេធាវីការពារក្តីអាចដឹង<អំពីរឿងនេះ ដែល>ថា <យ៉ាងហោចណាស់មាន>ការសម្ភាសទៅលើកម្មាភិបាល<>ដែលត្រូវបានគេបញ្ជូនទៅកំពង់ចាម <ដែល>អាចថាមានប្រយោជន៍ ហើយយើងអាចរៀបចំសំណួរដើម្បីសាកសួរទៅលើសាក្សីបែបនេះ។ ដូច្នេះ ខ្ញុំនឹងជម្រាបជូនតុលាការនៅពេលដែលការបង្ហាញឯកសារថ្មីៗត្រូវបានបង្ហាញ ហើយយើងដឹងអំពីបញ្ហាទាក់ទងទៅនឹងសាក្សី។ ដូច្នេះ ខ្ញុំគិតថាវាគ្រាន់តែជា -- តាមដែលខ្ញុំដឹងក្នុងចំណោមឯកសារជាង២២០ហ្នឹង គឺមិនមានពាក់ព័ន្ធទៅនឹងត្រាំកក់នោះឡើយ។ <ប៉ុន្តែមានការសម្ភាស>ពាក់ព័ន្ធទៅនឹង<ភូមិភាគកណ្តាល និង>ការបោសសំអាត<>។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគ្រាន់តែជាការស្នើសុំដល់ព្រះរាជអាជ្ញា ថាតើយើងអានឯកសារជាង៣០០ទំព័រហ្នឹងអានដោយរបៀបណា -- ៣០០០ទំព័រហ្នឹងអានដោយរបៀបណានៅត្រឹមថ្ងៃស្អែកនោះ។ យើងត្រូវអានទាំងអស់មុនថ្ងៃចន្ទសប្តាហ៍ក្រោយ ឬមួយក៏យ៉ាងម៉េច? តើលោកព្រះរាជអាជ្ញាមានគំនិត ឬក៏មានទស្សនៈបែបណាដែរ? ចំពោះយើងគឺយើងមិនអាចអានឲ្យអស់ ហើយពិភាក្សាជាមួយកូនក្តីយើងខ្ញុំបាននោះឡើយ។ ខ្ញុំគិតថានេះវាដូចជារឿងមួយមិនពាក់ព័ន្ធទេ។ សូមអរគុណ។

**លោក ឌេល លីសាក់៖**

វាមិនមែនជារឿងមិនពាក់ព័ន្ធនោះទេ ព្រោះថា អង្គជំនុំជម្រះកំពុងតែពិចារណាអំពីសាក្សីដែលត្រូវកោះហៅនៅសប្តាហ៍ក្រោយ។ ដូច្នេះ ខ្ញុំគ្រាន់តែជូនដំណឹងទៅដល់អង្គជំនុំជម្រះ ក៏ដូចជាភាគីនានាដែលថា <>សាក្សី<ម្នាក់ក្នុងចំណោមសាក្សីដែលនៅសល់ពាក់ព័ន្ធនឹងត្រាំកក់> មានព័ត៌មាន<បន្ថែម

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទៅ>នឹងត្រាំកក់។ ដូច្នេះ<មានតំបន់ត្រួតគ្នាមួយពាក់ព័ន្ធទៅនឹងកំណត់ហេតុស្ដាប់ចម្លើយរបស់>សាក្សី <មួយចំនួន>។ វាអាចនឹង<ជាប់>ពាក់ព័ន្ធចំពោះមេធាវីការពារក្ដី<។ យើងបានកំណត់អត្តសញ្ញាណនៅក្នុងឯកសារដែលបាន>បង្ហាញ< ថាមួយណាដែល>ពាក់ព័ន្ធទៅនឹងការបោសសម្អាតនៅភូមិឧត្តរ <>។

ដូច្នេះ <គឺមាននៅទីនោះរួចហើយ។ វា>អាស្រ័យទៅលើអង្គជំនុំជម្រះក្នុងការសម្រេចកាលបរិច្ឆេទសម្រាប់សាក្សី។

[១១:២៧:០២]

**លោក អាកទូរ វែកកែន៖**

ខ្ញុំមានសំណួរបន្ថែមទៅសហព្រះរាជអាជ្ញា។ តើលោក<អាចប្រាប់យើងបានទេ>ថា តើកំណត់ហេតុ២០ <ឬ>២៥<ណា> ដែល<ធ្វើឱ្យ>យើងចាប់អារម្មណ៍ក្នុងចំណោមឯកសារ<២២៦នោះ>?

**លោក ឌេល លីសាក់៖**

ឧបសម្ព័ន្ធដែលផ្ដល់ជាមួយញត្តិនោះ គឺជាអត្ថបទដែលពាក់ព័ន្ធមួយ ហើយខ្ញុំនឹងបញ្ជូនអ៊ីម៉ែលទៅជូនលោក។ ហើយខ្ញុំនឹងកំណត់នៅក្នុងចំណោម២៥ចម្លើយហ្នឹង ថាតើអ្នកណាជាកម្មាភិបាលមកពី<ភូមិភាគ>និរតីបញ្ជូនមកខាង<ភូមិភាគកណ្ដាល>។ ពាក់ព័ន្ធទៅនឹងការបោសសម្អាតនៅភូមិឧត្តរ គឺយើងមានប្រធានបទពាក់ព័ន្ធដែលត្រូវបានគេកំណត់រួចទៅហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ប៉ុណ្ណឹងបានហើយណ៎ះ! ចង់និយាយ? អញ្ជើញ!

**លោក អាកទូរ វែកកែន៖**

យើងអត់មានឧបសម្ព័ន្ធទេ។ អ៊ីចឹងលោកព្រះរាជអាជ្ញាសូមផ្ដល់ព័ត៌មានលម្អិតពាក់ព័ន្ធនឹងចំណុចនេះផង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយទំនងជាអង្គជំនុំជម្រះបាននឹងកំពុងតែមានបញ្ហាប្រឈមទៅលើការរៀបចំកាលវិភាគសវនាការជាបន្តបន្ទាប់ ដោយមានមូលហេតុនៃការដាក់ឯកសារថ្មីៗជាបន្តបន្ទាប់យ៉ាងច្រើននេះ។ ហើយក្រៅពីនេះមានបញ្ហាផ្សេងៗទៀត ដូចជាសាក្សីវ័យចំណាស់ ដូចជាថ្ងៃនេះជាក់ស្ដែងគឺគាត់

មានបញ្ហាសុខភាពមិនអាចផ្តល់សក្ខីកម្មបានជាដើម។ អ៊ីចឹង គម្រោងផែនការក្នុងការរៀបចំសវនាការ និងការកោះហៅសាក្សី ឬក៏បុគ្គលដែលមកផ្តល់សក្ខីកម្មនេះ គឺកំពុងតែមានបញ្ហាប្រឈម ទី១។ ទី២ គឺទំនងជាដោយសារមូលហេតុបញ្ហានេះដែលវាមិនជាការងាយ ដូច្នេះហើយទើបអង្គជំនុំជម្រះរហូតដល់ម៉ោងនេះ មិនទាន់មានឱកាសនៅក្នុងការជម្រាបជូន លទ្ធភាពជម្រាបជូនដល់ភាគីពាក់ព័ន្ធអំពីថាតើខ្លួនត្រូវស្តាប់សក្ខីកម្ម ឬបុគ្គលណាមួយនៅថ្ងៃចន្ទសប្តាហ៍ក្រោយទេ។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះបានជម្រាបអំមិញថា នឹងជាលទ្ធផលនៃកិច្ចប្រជុំពិភាក្សាផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងនៅល្ងាចនេះ ដើម្បីពិភាក្សាជាបន្ទាន់ ថាតើសម្រេចយកសាក្សី ឬបុគ្គលមួយណា ដើម្បីស្តាប់សក្ខីកម្មបន្តនៅថ្ងៃចន្ទ ឬក៏នៅក្នុងសប្តាហ៍ក្រោយនេះ ដើម្បីជម្រាបជូនភាគីបានជ្រាបជាមុននៅល្ងាចនេះ និងថ្ងៃស្អែក។

បាទ ឥឡូវនេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកបន្តធ្វើនៅថ្ងៃចន្ទ ដែលនឹងចាប់ផ្តើម -- ថ្ងៃចន្ទ ទី២៣ ខែមីនា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាដែលបានកំណត់នេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.កវិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការវិញនៅព្រឹកថ្ងៃចន្ទ ឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១១:៣០ នាទី)*